**រាជរដ្ឋាភិបាលកម្ពុជា**

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

# សេចក្តីណែនាំបច្ចេកទេស

# ស្តីពី

# ការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ

**រៀបចំដោយអនុគណៈកម្មាធិកាផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិរបស់ គ.ជ.អ.ប**

**ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០**

# មាតិកា


មាតិកា.....i

ប្រកាសអន្តរក្រសួងស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ.....iv

**១. គោលការណ៍.....១**

**២. យន្តការគាំទ្រ និងតួនាទី.....១**

២.១. ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ.....១

២.២. គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ.....២

២.៣. គណៈអភិបាលក្រុង ស្រុក ខណ្ឌ.....២

២.៤. ក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ.....២

២.៥. ការិយាល័យនានានៃសាលាក្រុង ស្រុក ខណ្ឌ.....២

២.៦. ការិយាល័យ អង្គភាពនានា.....៣

២.៧. ក្រុមប្រឹក្សាឃុំ សង្កាត់.....៣

២.៨. ប្រជាពលរដ្ឋ.....៣

២.៩. អង្គការសង្គមស៊ីវិល និងវិស័យឯកជន.....៣

**៣. ទម្រង់នៃសៀវភៅផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ.....៣**

**៤. សេចក្តីពន្យល់ខ្លឹមសារនៃទម្រង់សៀវភៅផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ.....៥**

សេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ.....៥

អារម្ភកថា.....៥

សេចក្តីផ្តើម.....៥

ផែនទីក្រុង ស្រុក ខណ្ឌ.....៥

**ជំពូកទី១ ÷ ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច.....៦**

១.១. សេចក្តីសង្ខេបទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច.....៦

១.២. ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម.....៧

១.២.១. ស្ថានភាពសេដ្ឋកិច្ច.....៧

១.២.២. ស្ថានភាពសង្គមកិច្ច.....៨

១.២.៣. ស្ថានភាពនៃការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន.....៩

១.២.៤. ស្ថានភាពនៃការគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ.....១០

១.២.៥. ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ.....១០

**ជំពូកទី២ ÷ ក្របខ័ណ្ឌអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ** ........ **១០**
២.១. ចក្ខុវិស័យអភិវឌ្ឍន៍ ........ ១០
២.២. គោលដៅអភិវឌ្ឍន៍ ........ ១១
២.៣. គោលបំណងអភិវឌ្ឍន៍ ........ ១១
២.៤. យុទ្ធសាស្ត្រអភិវឌ្ឍន៍ ........ ១១
២.៤.១. យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច ........ ១៣
២.៤.២. យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច ........ ១៣
២.៤.៣. យុទ្ធសាស្ត្រប្រើប្រាស់ដីធ្លី និងគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ........ ១៣
២.៤.៤. យុទ្ធសាស្ត្រគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ ........ ១៣
២.៤.៥. យុទ្ធសាស្ត្រគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ........ ១៤
២.៥. ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ........ ១៤
**ជំពូកទី៣ ÷ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍** ........ **១៤**
**ឧបសម្ព័ន្ធ** ........ **១៤**
**៥. ដំណើរការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ** ........ **១៥**
**ជំហានទី១ ÷ ការត្រៀមរៀបចំសម្រាប់ការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ** ........ **១៦**
១.១. គោលបំណង ........ ១៦
១.២. លទ្ធផលរំពឹងទុក ........ ១៦
១.៣. ដំណើរការ ........ ១៦
១.៣.១. កិច្ចប្រជុំណែនាំ ........ ១៦
១.៣.២. ការរៀបចំគោលការណ៍ណែនាំផ្នែកគោលនយោបាយ ........ ១៩
១.៣.៣. ការរៀបចំប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍ ........ ២២
១.៣.៤. ការរៀបចំវិឌ្ឍនភាពរបស់ក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ........ ២៣
១.៣.៥. ការរៀបចំបញ្ជីឯកសារពាក់ព័ន្ធនានា ........ ២៣
**ជំហានទី២ ÷ ការផ្សព្វផ្សាយព័ត៌មានអំពីការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ** ........ **២៧**
២.១. គោលបំណង ........ ២៧
២.២. លទ្ធផលរំពឹងទុក ........ ២៧
២.៣. ដំណើរការ ........ ២៧
**ជំហានទី៣ ÷ ការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ** ........ **២៩**
៣.១. គោលបំណង ........ ២៩
៣.២. លទ្ធផលរំពឹងទុក ........ ២៩
៣.៣. ដំណើរការ ........ ២៩

៣.៣.១. ការវិភាគស្ថានភាពក្រុង ស្រុក ខណ្ឌ ........ ២៩
៣.៣.២. ការរៀបចំក្របខ័ណ្ឌអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ........ ៤១
៣.៣.៣. ការរៀបចំយុទ្ធសាស្ត្រតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ ........ ៤១
៣.៣.៤. ការសរសេរសេចក្តីព្រាងផែនការអភិវឌ្ឍន៍ ........ ៤១
៣.៣.៥. កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ........ ៤១
៣.៣.៦. ការពិនិត្យ និងផ្តល់យោបល់របស់គណៈអភិបាលក្រុង ស្រុក ខណ្ឌទៅលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ........ ៤៣
៣.៣.៧. ការពិនិត្យ និងផ្តល់យោបល់របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុង ស្រុក ខណ្ឌទៅលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ........ ៤៣
**ជំហានទី៤ ÷ ការអនុម័តផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ........ ៤៤**
៤.១. គោលបំណង ........ ៤៤
៤.២. លទ្ធផលរំពឹងទុក ........ ៤៤
៤.៣. កិច្ចដំណើរការ ........ ៤៤
៤.៣.១. ការងារមុនសម័យប្រជុំក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ........ ៤៤
៤.៣.២. ការប្រជុំក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ........ ៤៤
៤.៣.៣. ការងារក្រោយកិច្ចប្រជុំក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ........ ៤៤

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ និងក្រសួងផែនការ**

លេខ ៤៦១៧ ប្រក

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការកសាងផែនការអភិវឌ្ឍន៍

## និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

********

## រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងផែនការ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងអនុក្រឹត្យលេខ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- យោងអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងអនុក្រឹត្យលេខ ២១៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

– យោងអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា១២នៃអនុក្រឹត្យស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

– យោងតាមការសម្រេចនៃកិច្ចប្រជុំ គ.ជ.អ.ប លើកទី៥ កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះ មានគោលបំណងណែនាំក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការកសាង អនុម័ត និងអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលសម្រាប់រដ្ឋបាលរបស់ខ្លួន ដោយមានការចូលរួម និងពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ស្របតាមខ្លឹមសារនៃសេចក្តីណែនាំបច្ចេកទេសស្តីពីការកសាងផែនការភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌក្រោមសុពលភាពនៃប្រកាសអន្តរក្រសួង នេះ ។

**ប្រការ ២.-**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំ(០៥)ឆ្នាំ យ៉ាងយូរបំផុត នៅក្នុងឆ្នាំទី២នៃអាណត្តិរបស់ខ្លួន ។ផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺជាឯកសារយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងជាមូលដ្ឋានសម្រាប់រៀបចំកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលនឹងត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ។

**ប្រការ ៣.-**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធានាឱ្យបានថា ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ កម្មវិធីវិនិយោគបីឆ្នាំរំកិល ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន ត្រូវបានដាក់បញ្ចូលនូវផែនការអភិវឌ្ឍន៍ និងថវិការបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអ្នកពាក់ព័ន្ធនានា ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ ។

**ប្រការ ៤.-**

ផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ត្រូវបញ្ចូលនូវផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌ និងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគសង្កាត់នានាក្នុងដែនសមត្ថកិច្ចរបស់រាជធានី ។

ផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ត្រូវបញ្ចូលនូវផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគសង្កាត់នានាក្នុងដែនសមត្ថកិច្ចរបស់ក្រុង ។

**ប្រការ ៥.-**

ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលដែលបានអនុម័តដោយក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺជាឯកសារផ្លូវការ ហើយក្រុមប្រឹក្សានីមួយៗត្រូវរៀបចំចាត់ចែងផ្សព្វផ្សាយឯកសារនេះជាសាធារណៈ និងដាក់តាំងនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

## ជំពូកទី២

## យន្តការ និងភារកិច្ចក្នុងការកសាងនិងអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

**ប្រការ ៦.-**

ដំណើរការនៃការកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ស្ថិតក្រោមការដឹកនាំ និងត្រួតពិនិត្យរួមរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ភារកិច្ចសំខាន់ៗរបស់ក្រុមប្រឹក្សារួមមាន :

- ត្រួតពិនិត្យ និងចូលរួមក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ណែនាំផ្នែកគោលនយោបាយសម្រាប់ដំណើរការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ពិនិត្យ និងអនុម័តប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ពិនិត្យ និងអនុម័តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ពិនិត្យ និងអនុម័តសំណើកែតម្រូវផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- តាមដាន និងវាយតម្លៃជារៀងរាល់ឆ្នាំលើការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

**ប្រការ ៧.-**

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចសំខាន់ៗដូចខាងក្រោម :

- ចូលរួមក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- សម្របសម្រួលការចូលរួមរបស់គ្រប់អ្នកពាក់ព័ន្ធក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ក្រៅពីភារកិច្ចខាងលើ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល មុននឹងក្រុមប្រឹក្សាធ្វើការពិនិត្យ និងអនុម័ត។

**ប្រការ ៨.-**

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន មានភារកិច្ចសំខាន់ៗដូចខាងក្រោម :

- ដឹកនាំ និងសម្របសម្រួលការងារកសាងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ស្របតាមការណែនាំរបស់ក្រុមប្រឹក្សា ដោយសហការជាមួយភាគីពាក់ព័ន្ធនានា
- ដឹកនាំសិក្ខាសាលា និងវេទិកាពិគ្រោះយោបល់នានា ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ដាក់ជូនក្រុមប្រឹក្សាពិនិត្យនិងអនុម័តសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- តាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

**ប្រការ ៩.-**

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ក្រុមការងារកសាងផែនការរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចសំខាន់ៗដូចខាងក្រោម :

- រៀបចំសេចក្តីព្រាងគោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សា
- រៀបចំសេចក្តីព្រាងប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ដឹកនាំ និងសម្របសម្រួលដំណើរការកសាងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- រៀបចំសិក្ខាសាលា និងវេទិកាពិគ្រោះយោបល់នានាជាមួយភាគីពាក់ព័ន្ធនានា ក្នុងដំណើរការកសាងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- រៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

**ប្រការ ១០.-**

ក្នុងដំណើរការកសាងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ទីចាត់ការ និងការិយាល័យនានានៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចសំខាន់ៗដូចខាងក្រោម :

- ជួយក្រុមប្រឹក្សា និងគណៈអភិបាលក្នុងការដឹកនាំ និងសម្របសម្រួលដំណើរការកសាង អនុម័ត តាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- សហការជាមួយក្រុមការងារកសាងផែនការក្នុងការដឹកនាំ និងសម្របសម្រួលការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ចូលរួមវិភាគស្ថានភាពនិងពិគ្រោះយោបល់ក្នុងការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- សម្របសម្រួល និងចូលរួមការបណ្តុះបណ្តាលអំពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ។

## ជំពូកទី៣

## ដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**ប្រការ ១១.-**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន តាមរយៈដំណើរការដែលមានការចូលរួមនិងពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ប្រភេទក្រុមប្រឹក្សាផ្សេងទៀត សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មន្ទីរ អង្គភាពពាក់ព័ន្ធ អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ដើម្បីរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រកបដោយគុណភាព និងស្របតាមគោលការណ៍ ដូចមានចែងក្នុងមាត្រា៥ នៃអនុក្រឹត្យលេខ២១៩ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំគោលការណ៍ណែនាំផ្នែកគោលនយោបាយ និងប្រតិទិនស្តីពីដំណើរការកសាងផែនការឱ្យបានច្បាស់លាស់ ដោយផ្តែកលើតម្រូវការជាអាទិភាពរបស់មូលដ្ឋាន សក្តានុពលរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគោលនយោបាយរបស់ជាតិ ។

គោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សា ត្រូវរៀបចំតាមរយៈដីកា ឬសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា។

ការចំណាយនានាសម្រាប់ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល គឺត្រូវរ៉ាប់រងដោយថវិការបស់ក្រុមប្រឹក្សានីមួយៗ។

**ប្រការ ១២.-**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរបស់ខ្លួន ដោយបញ្ចូលនូវខ្លឹមសារសំខាន់ៗមួយចំនួនដូចខាងក្រោម :

- **ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច :** រៀបរាប់ដោយសង្ខេបអំពីព័ត៌មានក្នុងស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈមនានាដែលពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច សង្គមកិច្ច ការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ការគ្រប់គ្រងគ្រោះមហន្តរាយ ការប្រែប្រួលអាកាសធាតុ និងស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល
- **ក្របខ័ណ្ឌអភិវឌ្ឍន៍ :** រៀបរាប់ពីចក្ខុវិស័យ គោលដៅ គោលបំណង និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនៃផែនការអភិវឌ្ឍន៍
- **ការតាមដាននិងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ :** រៀបរាប់អំពីអ្នកទទួលខុសត្រូវនិងអ្នកចូលរួមក្នុងការវាយតម្លៃ វិធីសាស្ត្រវាយតម្លៃ និងការរៀបចំរបាយការណ៍។

**ប្រការ ១៣.-**

ក្នុងការកសាងផែនការអភិវឌ្ឍន៍ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវយកចិត្តទុកដាក់លើសកម្មភាពសំខាន់ៗមួយចំនួនដូចខាងក្រោម :

- ការត្រៀមរៀបចំសម្រាប់ការកសាងផែនការអភិវឌ្ឍន៍
- ការផ្សព្វផ្សាយពត៌មានអំពីដំណើរការ និងនីតិវិធីសម្រាប់ការកសាងផែនការអភិវឌ្ឍន៍
- ការកសាងផែនការអភិវឌ្ឍន៍ តាមរយៈការវិភាគស្ថានភាព និងការរៀបចំក្របខ័ណ្ឌអភិវឌ្ឍន៍ និង
- ការអនុម័តផែនការអភិវឌ្ឍន៍

**ប្រការ ១៤.-**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន ដោយបញ្ចូលនូវខ្លឹមសារសំខាន់ៗមួយចំនួនដូចខាងក្រោម :

- **ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច :** រៀបរាប់ដោយសង្ខេបអំពីព័ត៌មានសេដ្ឋកិច្ច សង្គមកិច្ច ក្នុងស្ថានភាពបច្ចុប្បន្ន បញ្ហាប្រឈម និងតម្រូវការជាអាទិភាពរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- **គម្រោងនៃកម្មវិធីវិនិយោគបីឆ្នាំរំកិល :** រៀបរាប់អំពីគម្រោងវិនិយោគ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងផែនការសកម្មភាពសម្រាប់អនុវត្តគម្រោងឆ្នាំទី១នៃកម្មវិធីវិនិយោគបីឆ្នាំរំកិល។
- **ការតាមដាននិងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគ :** រៀបរាប់អំពីអ្នកទទួលខុសត្រូវ និងអ្នកចូលរួមក្នុងការវាយតម្លៃ វិធីសាស្ត្រវាយតម្លៃ និងការរៀបចំរបាយការណ៍។

**ប្រការ ១៥.-**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន ដោយផ្អែកលើផែនការអភិវឌ្ឍន៍។ កម្មវិធីវិនិយោគបីឆ្នាំរំកិល ត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។ សកម្មភាពសំខាន់ៗនៃដំណើរការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរួមមាន :

- ការវិភាគស្ថានភាព ដោយផ្តោតលើការកំណត់បញ្ហា និងតម្រូវការជាអាទិភាព
- ការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ការអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិល

**ប្រការ ១៦.-**

ក្រសួងផែនការត្រូវជួយក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការរៀបចំព័ត៌មានស្តីពីវឌ្ឍនភាព នៃការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា កម្រងឯកសារស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទិន្នន័យមូលដ្ឋានឃុំ សង្កាត់ និងទិន្នន័យផ្សេងទៀតដែលពាក់ព័ន្ធនឹងការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**ប្រការ ១៧.-**

ក្រោយពេលដែលក្រុមប្រឹក្សារាជធានី ខេត្ត បានពិនិត្យ និងអនុម័តលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្តរួចហើយ គណៈអភិបាលរាជធានី ខេត្តត្រូវធ្វើការកែសម្រួលដោយផ្អែកតាមការសម្រេចរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ហើយដាក់ជូនអភិបាលរាជធានី ខេត្តនូវសេចក្តីព្រាងផែនការដែលបានកែសម្រួលនេះ ដើម្បីពិនិត្យ និងផ្ញើមកលេខាធិការដ្ឋាន គ.ជ.អ.ប។ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវធ្វើការថតចម្លងសេចក្តីព្រាងនេះជូនក្រសួងមហាផ្ទៃ ក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងត្រូវធ្វើការសម្របសម្រួល ពិនិត្យ ពិគ្រោះយោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ជាមួយក្រសួងទាំងបីខាងលើនេះ ព្រមទាំងជាមួយស្ថាប័នពាក់ព័ន្ធនានា ដើម្បីពិនិត្យ និងផ្តល់យោបល់លើភាពស្របច្បាប់ និងសង្គតិភាពនៃផែនការនេះជាមួយគោលនយោបាយជាតិ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។ ក្រោយពេលពិនិត្យ និងពិគ្រោះយោបល់រួចរាល់ហើយ លេខាធិការដ្ឋានត្រូវធ្វើកំណត់បង្ហាញសុំយោបល់មករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ និងផ្តល់អនុលោមភាព។ ការពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ត្រូវធ្វើឡើងក្នុងរយៈពេល៣០ថ្ងៃ គិតពីថ្ងៃដែលទទួលបានការស្នើសុំពិនិត្យ និងផ្តល់យោបល់របស់អភិបាលរាជធានី ខេត្ត។ រយៈពេល៣០ថ្ងៃនេះ រួមមានពេលវេលាចំណាយសម្រាប់ការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ការធ្វើទំនាក់ទំនងជាមួយអភិបាលរាជធានី ខេត្ត ដើម្បីស្រាយបំភ្លឺ និងឯកភាពលើយោបល់ដែលផ្តល់ដោយក្រសួងមហាផ្ទៃលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត។

ក្នុងករណីមិនមានការឯកភាពគ្នារវាងអភិបាលរាជធានី ខេត្ត និងក្រសួងមហាផ្ទៃអំពីខ្លឹមសារសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ក្រសួងមហាផ្ទៃត្រូវរាយការណ៍ និងស្នើសុំ គ.ជ.អ.ប ដើម្បីធ្វើការសម្របសម្រួលដោះស្រាយ។

ក្នុងរយៈពេល៣០ថ្ងៃ បើគ្មានការឆ្លើយតបជាលាយល័ក្ខណ៍អក្សរពីក្រសួងមហាផ្ទៃផ្ញើទៅអភិបាលរាជធានី ខេត្តទេ នោះសេចក្តីព្រាងផែនការអភិវឌ្ឍន៍ ត្រូវចាត់ទុកថាទទួលបានអនុលោមភាពពីក្រសួងមហាផ្ទៃ។

**ប្រការ ១៨.-**

ក្រោយពេលដែលក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ បានពិនិត្យ និងអនុម័តលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌរួចហើយ គណៈអភិបាលក្រុង ស្រុក ខណ្ឌត្រូវធ្វើការកែសម្រួលដោយផ្អែកតាមការសម្រេចរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ហើយដាក់ជូនអភិបាលក្រុង ស្រុក ខណ្ឌនូវសេចក្តីព្រាងផែនការដែលបានកែសម្រួលនេះ ដើម្បីពិនិត្យ និងផ្ញើជូនអភិបាលរាជធានី ខេត្ត ដើម្បីពិនិត្យ និងផ្តល់យោបល់លើភាពស្របច្បាប់ និងសង្គតិភាពនៃផែនការនេះជាមួយគោលនយោបាយជាតិ ច្បាប់ និងលិខិតបទដ្ឋាននានា។ អភិបាលរាជធានី ខេត្ត ត្រូវធ្វើការពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្នុងរយៈពេល៣០ថ្ងៃ គិតពីថ្ងៃដែលទទួលបានការស្នើសុំពិនិត្យ និងផ្តល់យោបល់ដោយអភិបាលក្រុង ស្រុក ខណ្ឌ ដោយសហការយ៉ាងជិតស្និទ្ធជាមួយមន្ទីរ អង្គភាពពាក់ព័ន្ធនានា។ រយៈពេល៣០ថ្ងៃនេះ រួមមានពេលវេលាចំណាយសម្រាប់ការធ្វើទំនាក់ទំនងរវាងអភិបាលក្រុង ស្រុក ខណ្ឌ ជាមួយនឹងអភិបាលរាជធានី ខេត្ត ដើម្បីស្រាយបំភ្លឺ និងឯកភាពលើយោបល់ដែលផ្តល់ដោយអភិបាលរាជធានី ខេត្ត លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ។

ក្នុងករណីមិនមានការឯកភាពគ្នារវាងអភិបាលក្រុង ស្រុក ខណ្ឌ និងអភិបាលរាជធានី ខេត្ត អំពីខ្លឹមសារនៃសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ អភិបាលរាជធានី ខេត្តត្រូវរាយការណ៍ និងស្នើសុំមកលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីធ្វើការសម្របសម្រួលដោះស្រាយ។

ក្នុងរយៈពេល៣០ថ្ងៃ បើគ្មានការឆ្លើយតបជាលាយល័ក្ខណ៍អក្សរពីអភិបាលរាជធានី ខេត្តទៅក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌទេ នោះសេចក្តីព្រាងផែនការអភិវឌ្ឍន៍ ត្រូវចាត់ទុកថាទទួលបានអនុលោមភាពពីអភិបាលរាជធានី ខេត្ត។

ក្នុងការពិនិត្យ និងផ្តល់យោបល់ទៅលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ អភិបាលរាជធានី ខេត្ត ត្រូវពិចារណាអំពីភាពស្របច្បាប់ និងសង្គតិភាពនៃខ្លឹមសារផែនការអភិវឌ្ឍន៍ទៅនឹងគោលនយោបាយជាតិ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។

**ប្រការ ១៩.-**

គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំបោះពុម្ព បែងចែក ផ្សព្វផ្សាយជាសាធារណៈនូវផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបានអនុម័តដោយក្រុមប្រឹក្សា និងតម្កល់ទុកនៅសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មន្ទីរផែនការរាជធានី ខេត្ត ការិយាល័យផែនការក្រុង ស្រុក ខណ្ឌ និងផ្ញើទៅក្រសួងផែនការ ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអ្នកពាក់ព័ន្ធដទៃទៀត។

**ប្រការ ២០.-**

ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងសំណើកែប្រែផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវតែអនុម័តដោយសម្លេងលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទាំងមូល។

ក្នុងករណីក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានរំលាយមុនអាណត្តិ យោងតាមមាត្រា២៤ នៃច្បាប់

ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌថ្មី អាចទទួលយកផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលកំពុងមានទាំងស្រុង ឬអាចរៀបចំកែសម្រួលផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនោះ សម្រាប់រយៈពេលអាណត្តិដែលនៅសល់ ។

## ជំពូកទី៤

## ការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**ប្រការ ២១.-**

បន្ទាប់ពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលត្រូវបានអនុម័ត ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការណែនាំឱ្យគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចាត់ចែងការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដោយមានតម្លាភាព មានគណនេយ្យភាព មានការចូលរួម និងមានប្រសិទ្ធភាព ។

**ប្រការ ២២.-**

អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តគម្រោង និងសកម្មភាពនានានៃផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដោយអនុលោមតាមច្បាប់ បទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ដូចជាការធ្វើលទ្ធកម្មការងារសាងសង់ សម្ភារៈ ឬទំនិញ និងសេវាកម្មជាដើម ។ល ។

## ជំពូកទី៥

## ការតាមដាន ការវាយតម្លៃ និងរបាយការណ៍

**ប្រការ ២៣.-**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការណែនាំឱ្យអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ធ្វើការតាមដាននិងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដោយរួមទាំងគម្រោងនិង សកម្មភាពនានាដែលអនុវត្ត និងគ្រប់គ្រងក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាដោយ :

- ប្រភេទក្រុមប្រឹក្សាដូចគ្នា
- ប្រភេទក្រុមប្រឹក្សាផ្សេងទៀត
- មន្ទីរ អង្គភាពនានា
- អ្នកពាក់ព័ន្ធផ្សេងទៀតដូចជា អង្គការសង្គមស៊ីវិល និងវិស័យឯកជននានា ។

**ប្រការ ២៤.-**

គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការវាយតម្លៃអំពីលទ្ធផល និងសមិទ្ធផលនៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលជារៀងរាល់ឆ្នាំ ប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងមានការចូលរួមពីអ្នកពាក់ព័ន្ធនានា ។

គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការវាយតម្លៃអំពីលទ្ធផល សមិទ្ធផល និងផលប៉ះពាល់នៃការអនុវត្តផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងរយៈពេល០៦ខែចុងក្រោយនៃអាណត្តិរបស់ក្រុមប្រឹក្សា ប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងមានការចូលរួមពីអ្នកពាក់ព័ន្ធនានា ។

នីតិវិធីនៃការវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមសេចក្តីណែនាំរបស់ គ.ជ.អ.ប ។

**ប្រការ ២៥.-**

នៅចុងឆ្នាំនីមួយៗ គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត ។ ខ្លឹមសាររបាយការណ៍នេះរួមមាន :

- វឌ្ឍនភាពការងារអនុវត្តក្នុងឆ្នាំកន្លងមក
- ទិសដៅការងារសម្រាប់អនុវត្តឆ្នាំខាងមុខ
- សេចក្តីសន្និដ្ឋានរួម ។

ក្រៅពីរបាយការណ៍ប្រចាំឆ្នាំស្តីពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំរបាយការណ៍ផ្សេងទៀត ដើម្បីរាយការណ៍ជូនក្រុមប្រឹក្សាជាប្រចាំ ។

**ប្រការ ២៦.-**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុម័តរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល និងរបាយការណ៍ស្តីពីលទ្ធផលនៃការតាមដាន និងវាយតម្លៃ មិនឱ្យលើសពីសែសិបប្រាំ(៤៥)ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំនីមួយៗ ។

របាយការណ៍ប្រចាំឆ្នាំរបស់រាជធានី ខេត្ត ត្រូវផ្ញើជូនគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងភាគីពាក់ព័ន្ធនានា ។

របាយការណ៍ប្រចាំឆ្នាំរបស់ក្រុង ស្រុក ខណ្ឌ ត្រូវផ្ញើជូនអភិបាលរាជធានី ខេត្ត គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងភាគីពាក់ព័ន្ធនានា ។

របាយការណ៍ប្រចាំឆ្នាំដែលបានអនុម័តដោយក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវតម្កល់ទុកនៅសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មន្ទីរ ការិយាល័យផែនការរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

## ជំពូកទី៦

## ការរៀបចំ និងការផ្សព្វផ្សាយសេចក្តីណែនាំស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**ប្រការ ២៧.-**

ក្រសួងផែនការ និងជាប្រធានអនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិនៃ គ.ជ.អ.ប ត្រូវសហការជាមួយក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានា ដើម្បីរៀបចំផ្សព្វផ្សាយ និងណែនាំឱ្យប្រើប្រាស់សេចក្តីណែនាំបច្ចេកទេសស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនេះ ស្របតាមខ្លឹមសារនិងសកម្មភាពសំខាន់ៗដូចមានចែងក្នុងប្រការ១៣ ប្រការ១៤ ប្រការ១៥ និងប្រការ១៦នៃប្រកាសនេះ ។

**ប្រការ ២៨.-**

ក្រសួងផែនការ និងជាប្រធានអនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិនៃ គ.ជ.អ.ប អាចធ្វើការកែសម្រួលសេចក្តីណែនាំស្តីពីការកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមការចាំបាច់ បន្ទាប់ពីបានពិភាក្សាជាមួយក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប និងអ្នកពាក់ព័ន្ធផ្សេងទៀត ។

**ប្រការ ២៩.-**

ក្រសួងផែនការនិងជាប្រធានអនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិនៃ គ.ជ.អ.ប ត្រូវសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប និងអ្នកពាក់ព័ន្ធនានា ដើម្បីរៀបចំឯកសារ កម្មវិធីផ្សព្វផ្សាយ និងការបណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធទាំងអស់ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អំពីនីតិវិធីកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដូចមានក្នុងសេចក្តីណែនាំបច្ចេកទេសនេះ ។

## ជំពូកទី៧

## អវសានបញ្ញត្តិ

**ប្រការ ៣០.-**

ប្រកាសនេះ ពុំមានអធិកភាពលើប្រកាសអន្តរក្រសួងស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំសង្កាត់ឡើយ ប៉ុន្តែប្រកាសទាំងពីរមានទំនាក់ទំនងជាមួយគ្នាយ៉ាងជិតស្និទ្ធ ជាពិសេសសម្រាប់សង្កាត់ដែលស្ថិតក្នុងដែនសមត្ថកិច្ចរាជធានី និងសង្កាត់ស្ថិតក្នុងដែនសមត្ថកិច្ចក្រុង ។

**ប្រការ ៣១.-**

ប្រកាស និងសេចក្តីណែនាំទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសអន្តរក្រសួងនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣២.-**

ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ ធ្នូ ឆ្នាំ២០១០

**ឧបនាយករដ្ឋមន្ត្រី** **ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** **រដ្ឋមន្ត្រីក្រសួងផែនការ**

**ស ខេង** **ឆាយ ថន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *សមាជិក "គ.ជ.អ.ប"*
- *ក្រសួង-ស្ថាប័នពាក់ព័ន្ធ*
  *"ដើម្បីជូនជ្រាប"*
- *សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់*
  *"ដើម្បីមុខការ"*
- *ឯកសារ-កាលប្បវត្តិ*

# សេចក្តីណែនាំបច្ចេកទេស
# ស្តីពីការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ

សេចក្តីណែនាំបច្ចេកទេសស្តីពីការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ត្រូវបានរៀបចំឡើងដោយផ្អែកលើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអនុក្រឹត្យនិងប្រកាសអន្តរក្រសួងស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

## ១. គោលការណ៍

ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ត្រូវផ្អែកលើគោលការណ៍សំខាន់ៗដូចខាងក្រោម ៖

១. ការចែករំលែកព័ត៌មាន

២. តម្លាភាព

៣. សង្គតិភាព និងសុខដុមនីយកម្ម

៤. ការចូលរួមពិគ្រោះយោបល់ជាទូទៅ

៥. ការឆ្លើយតបនឹងតម្រូវការ

៦. គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ

៧. ប្រសិទ្ធភាព និងសុក្រឹត្យភាពសេដ្ឋកិច្ច និងសង្គម

៨. ការធានាចីរភាពធនធានធម្មជាតិ និងបរិស្ថាន

៩. ការធានាសមធម៌

## ២. យន្តការគាំទ្រ និងតួនាទី

### ២.១. ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មានភារកិច្ចសំខាន់ៗ ដូចខាងក្រោម ៖

- ណែនាំផ្អែកគោលនយោបាយទូទៅសម្រាប់រៀបចំខ្លឹមសារផែនការអភិវឌ្ឍន៍
- ពិនិត្យ និងអនុម័តប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍
- ចូលរួមក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍
- ពិនិត្យ និងអនុម័តផែនការអភិវឌ្ឍន៍
- ពិនិត្យ និងអនុម័តសំណើកែតម្រូវផែនការអភិវឌ្ឍន៍ក្នុងករណីចាំបាច់
- តាមដាន និងវាយតម្លៃជារៀងរាល់ឆ្នាំលើការអនុវត្តផែនការអភិវឌ្ឍន៍

### ២.២. គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មានភារកិច្ចសំខាន់ៗដូចខាងក្រោម ៖

- ចូលរួមក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍
- សម្របសម្រួលការចូលរួមរបស់គ្រប់អ្នកពាក់ព័ន្ធក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍
- ពិនិត្យ និងជូនយោបល់ទៅក្រុមប្រឹក្សា មុនធ្វើការអនុម័តលើសេចក្ដីព្រាងផែនការអភិវឌ្ឍន៍

### ២.៣. គណៈអភិបាលក្រុង ស្រុក ខណ្ឌ

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ គណៈអភិបាលក្រុង ស្រុក ខណ្ឌក្នុងនាមក្រុមប្រឹក្សា មានភារកិច្ចសំខាន់ៗដូចខាងក្រោម ៖

- ដឹកនាំ និងសម្របសម្រួលការងារកសាងផែនការអភិវឌ្ឍន៍ ស្របតាមការណែនាំពីក្រុមប្រឹក្សាដោយសហការជាមួយភាគីពាក់ព័ន្ធនានា
- ដឹកនាំសិក្ខាសាលា វេទិកាពិគ្រោះយោបល់នានា ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍
- ពិនិត្យ និងផ្ដល់យោបល់ទៅលើសេចក្ដីព្រាងផែនការអភិវឌ្ឍន៍ មុនក្រុមប្រឹក្សាអនុម័ត
- ដាក់ជូនក្រុមប្រឹក្សា ពិនិត្យនិងអនុម័តផែនការអភិវឌ្ឍន៍
- តាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍

### ២.៤. ក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ក្រុមការងារកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគក្រុង ស្រុក ខណ្ឌ មានភារកិច្ចសំខាន់ៗដូចខាងក្រោម ៖

- រៀបចំសេចក្ដីព្រាងគោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សា
- រៀបចំសេចក្ដីព្រាងប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍
- ដឹកនាំ និងសម្របសម្រួលដំណើរការកសាងផែនការអភិវឌ្ឍន៍
- រៀបចំសិក្ខាសាលា វេទិកាពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធនានាក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍
- រៀបចំសេចក្ដីព្រាងផែនការអភិវឌ្ឍន៍

### ២.៥. ការិយាល័យនានានៃសាលាក្រុង ស្រុក ខណ្ឌ

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍក្រុង ស្រុក ខណ្ឌ ការិយាល័យនានានៃសាលាក្រុង ស្រុក ខណ្ឌ មានភារកិច្ចសំខាន់ៗ ដូចខាងក្រោម ៖

- ជួយក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុក ខណ្ឌក្នុងការដឹកនាំ និងសម្របសម្រួលដំណើរការកសាង អនុម័ត តាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ
- សហការជាមួយក្រុមការងារកសាងផែនការក្រុង ស្រុក ខណ្ឌក្នុងការដឹកនាំ និងសម្របសម្រួលការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ

- ចូលរួមក្នុងការវិភាគស្ថានភាពក្រុង ស្រុក ខណ្ឌ
- ចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់នានាស្តីពីការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ

### ២.៦. ការិយាល័យ អង្គភាពនានា

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ការិយាល័យ អង្គភាពនានាក្នុងក្រុង ស្រុក ខណ្ឌ មានភារកិច្ចសំខាន់ៗដូចខាងក្រោម ៖

- ចូលរួម និងផ្តល់នូវព័ត៌មានពាក់ព័ន្ធនឹងការកសាងផែនការអភិវឌ្ឍន៍
- ចូលរួមក្នុងការវិភាគស្ថានភាពក្រុង ស្រុក ខណ្ឌ
- ចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់នានាស្តីពីការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ

### ២.៧. ក្រុមប្រឹក្សាឃុំ សង្កាត់

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវ ៖

- ចូលរួម និងផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ
- ចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់នានាស្តីពីការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ

### ២.៨. ប្រជាពលរដ្ឋ

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ប្រជាពលរដ្ឋក្នុងក្រុង ស្រុក ខណ្ឌ ត្រូវ ៖

- កំណត់បញ្ហា និងតម្រូវការអាទិភាពនានា តាមរយៈការចូលរួមក្នុងដំណើរការកសាងផែនការឃុំ សង្កាត់
- ចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់នានាស្តីពីការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ
- ចូលរួមក្នុងការតាមដាន និងវាយតម្លៃលើការអនុវត្តផែនការអភិវឌ្ឍន៍

### ២.៩. អង្គការសង្គមស៊ីវិល និងវិស័យឯកជន

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ អង្គការសង្គមស៊ីវិល និងវិស័យឯកជនក្នុងក្រុង ស្រុក ខណ្ឌ ត្រូវ ៖

- ចូលរួម និងផ្តល់នូវព័ត៌មាននានាដែលពាក់ព័ន្ធនឹងការកសាងផែនការអភិវឌ្ឍន៍
- ចូលរួមក្នុងការវិភាគស្ថានភាពក្រុង ស្រុក ខណ្ឌ
- ចូលរួមក្នុងការពិភាក្សា និងពិគ្រោះយោបល់នានាដែលពាក់ព័ន្ធនឹងដំណើរការកសាងផែនការអភិវឌ្ឍន៍។

## ៣. ទម្រង់នៃសៀវភៅផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ

- សេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ
- អារម្ភកថា
- សេចក្តីផ្តើម
- ផែនទីក្រុង ស្រុក ខណ្ឌ

**ជំពូកទី១ ៖ ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច**

១.១. សេចក្តីសង្ខេបទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច

១.២. ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម

១.២.១. ស្ថានភាពសេដ្ឋកិច្ច

១.២.២. ស្ថានភាពសង្គមកិច្ច

១.២.៣. ស្ថានភាពនៃការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន

១.២.៤. ស្ថានភាពនៃការគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ

១.២.៥. ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

**ជំពូកទី២ ៖ ក្របខ័ណ្ឌអភិវឌ្ឍន៍របស់ក្រុង ស្រុក ខណ្ឌ**

២.១. ចក្ខុវិស័យអភិវឌ្ឍន៍

២.២. គោលដៅអភិវឌ្ឍន៍

២.៣. គោលបំណងអភិវឌ្ឍន៍

២.៤. យុទ្ធសាស្ត្រអភិវឌ្ឍន៍

២.៤.១. យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច

២.៤.២. យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច

២.៤.៣. យុទ្ធសាស្ត្រប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន

២.៤.៤. យុទ្ធសាស្ត្រគ្រប់គ្រងគ្រោះមហន្តរាយ និងសម្របសម្រួលការប្រែប្រួលអាកាសធាតុ

២.៤.៥. យុទ្ធសាស្ត្រគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

២.៥. ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម

**ជំពូកទី៣ ៖ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍**

**ឧបសម្ព័ន្ធ**

## ៤. សេចក្តីពន្យល់ខ្លឹមសារនៃទម្រង់សៀវភៅផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ

- **សេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ**

  បន្ទាប់ពីគម្រប គឺជាសេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ។ ខ្លឹមសារសំខាន់ៗដែលត្រូវបញ្ចូលក្នុងសេចក្តីសម្រេច មានដូចជា ការប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ដែលបានអនុម័តដោយក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ ការណែនាំដល់គណៈអភិបាលក្រុង ស្រុក ខណ្ឌក្នុងការផ្សព្វផ្សាយ ការអនុវត្ត និងការតាមដាននិងការវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍។ សេចក្តីសម្រេចនេះត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ។

- **អារម្ភកថា**

  បន្ទាប់ពីទំព័រមាតិកា គឺទំព័រអារម្ភកថា។ អារម្ភកថាមិនគួរសរសេរវែងពេក (យ៉ាងច្រើនត្រឹមមួយទំព័រ)។ អារម្ភកថាត្រូវបង្ហាញពីសារប្រយោជន៍នៃផែនការអភិវឌ្ឍន៍ ការថ្លែងអំណរគុណចំពោះអ្នកដែលបានចូលរួមកសាងផែនការអភិវឌ្ឍន៍ និងសេចក្តីសង្ឃឹមដែលនឹងទទួលបានការគាំទ្រពីអ្នកពាក់ព័ន្ធ។ អារម្ភកថាត្រូវរក្សាក្នុងមួយទំព័រដាច់ដោយឡែក។

- **សេចក្តីផ្តើម**

  បន្ទាប់ពីទំព័រអារម្ភកថា គឺសេចក្តីផ្តើម។ សេចក្តីផ្តើមត្រូវសរសេរពីមូលហេតុដែលនាំឱ្យមានការរៀបចំផែនការអភិវឌ្ឍន៍ និងគោលបំណង និងសង្ខេបដំណើរការនៃការរៀបចំផែនការអភិវឌ្ឍន៍។ សេចក្តីផ្តើមមិនគួរសរសេរវែងពេក ហើយក៏ពុំចាំបាច់ត្រូវតែមានក្នុងមួយទំព័រដាច់ដោយឡែកនោះទេ (មានន័យថា អាចតទំព័រ)។

- **ផែនទីក្រុង ស្រុក ខណ្ឌ**

  គប្បីប្រើផែនទីក្រុង ស្រុក ខណ្ឌ ដែលបង្ហាញពីលក្ខណៈភូមិសាស្ត្រ ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ធនធានធម្មជាតិ និងរដ្ឋបាលក្នុងក្រុង ស្រុក ខណ្ឌ។ ជាការប្រសើរ ផែនទីនេះគួររៀបចំនៅលើក្រដាសទំហំ A3។ លើផែនទីត្រូវប្រើនិមិត្តសញ្ញាសម្រាប់តាងឱ្យវត្ថុដែលកំពុងមានក្នុងក្រុង ស្រុក ខណ្ឌ ដូចជា និមិត្តសញ្ញានៃប្រព័ន្ធផ្លូវថ្នល់ ស្ពាន លូដោះទឹក ប្រព័ន្ធប្រឡាយទឹក ទីតាំងរដ្ឋបាល ទីតាំងសាលារៀន ទីតាំងផ្តល់សេវាសុខភាពសាធារណៈ ទីតាំងសាសនា វាលស្រែ ធនធានធម្មជាតិ ... ។ល។

# ជំពូកទី១ ÷ ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច

## ១.១. សេចក្តីសង្ខេបទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច

ព័ត៌មានសំខាន់ៗក្នុងក្រុង ស្រុក ខណ្ឌ

| បរិយាយ | ឯកតា | ឆ្នាំ២០១០ |
|---|---|---|
| ផ្ទៃដីក្រុង ស្រុក ខណ្ឌ | គ.ម២ | |
| ចំនួនឃុំ សង្កាត់ | ឃុំ សង្កាត់ | |
| ចំនួនភូមិ | ភូមិ | |
| ចំនួនប្រជាជនសរុប | នាក់ | |
| ចំនួនស្ត្រីសរុប | នាក់ | |
| កំណើនប្រជាជនប្រចាំឆ្នាំ | % | |
| ចំនួនគ្រួសារសរុប | គ្រួសារ | |
| អត្រាមេគ្រួសារជាស្ត្រី | % | |
| អត្រាគ្រួសារមានមុខរបរ..........ជាចម្បង | % | |
| អត្រាកុមារអាយុ៦-១៤ឆ្នាំ មិនបានចូលរៀន | % | |
| អត្រាអ្នកមិនចេះអក្សរអាយុពី១៥-៦០ឆ្នាំ | % | |
| អត្រាស្ត្រីមិនចេះអក្សរអាយុពី១៥-៦០ឆ្នាំ | % | |
| ចំនួនស្ត្រីសម្រាលកូនសរុប | នាក់ | |
| អត្រាស្ត្រីសម្រាលកូនដោយពេទ្យឆ្មប | % | |
| មរណភាពមាតាក្នុង១០ម៉ឺនកំណើតក្រោយពេលសម្រាលកូនពី 0-១ខែ | នាក់ | |
| អត្រាគ្រួសារប្រើប្រាស់ទឹកម៉ាស៊ីន | % | |
| អត្រាគ្រួសារប្រើប្រាស់អណ្តូងទឹកស្អាត | % | |
| សមាមាត្រគ្រួសារមានបង្គន់អនាម័យប្រើប្រាស់ | % | |

តួលេខដែលយកមកបំពេញក្នុងតារាងខាងលើនេះ ត្រូវស្រង់ចេញពីសៀវភៅទិន្នន័យភូមិ ឃុំ សង្កាត់ និងឯកសារព័តិមានស្ថានភាពក្រុង ស្រុក ខណ្ឌ ដែលបានធ្វើបច្ចុប្បន្នភាពចុងក្រោយគេ។ តួលេខមួយចំនួន ដូចជា ៖ ផ្ទៃដី ចំនួនភូមិ ឃុំ សង្កាត់ នោះក្រុង ស្រុក ខណ្ឌ ត្រូវបំពេញដោយខ្លួនឯង។ ក្រុង ស្រុក ខណ្ឌ អាចបន្ថែមព័តិមានទៀតដែលខ្លួនយល់ថាមានសារៈសំខាន់ដល់ការរំលេចខ្លឹមសារផែនការអភិវឌ្ឍន៍របស់ខ្លួន ដូចជា សូចនាករនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សគោលដៅ និងចំណុចដៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ តែមិនគួរបន្ថែមច្រើនពេក នាំឱ្យព័តិមានទាំងនោះប្រែជាមិនសំខាន់ទៅវិញ។

## ១.២. ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម

ក្នុងចំណុចនេះ ត្រូវរៀបរាប់អំពី**អ្វីខ្លះដែលក្រុង ស្រុក ខណ្ឌមាន**(សក្តានុពល) សម្រាប់បម្រើឱ្យសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និង**អ្វីខ្លះដែលជាឧបសគ្គ ឬជាបញ្ហាប្រឈម**(កត្តាធ្វើឱ្យរាំងស្ទះ) ដល់ការអភិវឌ្ឍន៍ និងការឆ្លើយតបទៅនឹងសេចក្តីត្រូវការទាំងនោះ។

ការសរសេរពីស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម ត្រូវផ្អែកលើលទ្ធផលនៃការវិភាគស្ថានភាពក្នុងជំហានទី៣នៃដំណើរការកសាងផែនការអភិវឌ្ឍន៍។ ក្នុងការបរិយាយ អាចបញ្ចូលតារាងទិន្នន័យ ឬក្រាហ្វិកសំខាន់ៗ និងត្រូវអនុវត្តតាមលំដាប់លំដោយដូចខាងក្រោម។

### ១.២.១. ស្ថានភាពសេដ្ឋកិច្ច

ផ្អែកតាមលទ្ធភាពនិងភាពជាក់ស្តែងដោយឡែកៗ ក្នុងចំណុចនេះ ក្រុង ស្រុក ខណ្ឌត្រូវធ្វើការកំណត់ និងសរសេរតាមបែបវិភាគពីសកម្មភាពសេដ្ឋកិច្ចចម្បងៗ និងបន្ទាប់បន្សំមួយចំនួនដែលមានក្នុង ក្រុង ស្រុក ខណ្ឌ ដោយផ្អែកលើលទ្ធផលវិភាគផ្នែកសេដ្ឋកិច្ច។

សកម្មភាពសេដ្ឋកិច្ចចម្បង គឺសំដៅលើសកម្មភាព ដែលប្រជាពលរដ្ឋភាគច្រើនក្នុងក្រុង ស្រុក ខណ្ឌ អនុវត្តដើម្បីយកផលមកធ្វើជាកម្លាំងស្នូលក្នុងការទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃ។ ចំណែកឯសកម្មភាពសេដ្ឋកិច្ចបន្ទាប់បន្សំ គឺសំដៅលើសកម្មភាពដែលប្រជាពលរដ្ឋមួយចំនួនក្នុងក្រុង ស្រុក ខណ្ឌអនុវត្តដើម្បីរកកម្រៃបន្ថែមសម្រាប់ការទ្រទ្រង់ជីវភាព (ទោះបីជាបរិមាណចំណូលពីសកម្មភាពសេដ្ឋកិច្ចបន្ទាប់បន្សំអាចច្រើនជាងចំណូលពីសកម្មភាពសេដ្ឋកិច្ចចម្បងក៏ដោយ)។

ឧទាហរណ៍ ៖ ក្នុងក្រុង ដែលមានប្រជាពលរដ្ឋភាគច្រើនប្រកបរបរជាអាជីវករ ដូច្នេះ សកម្មភាពសេដ្ឋកិច្ចចម្បង គឺអាជីវកម្ម ទោះបីជាចំណូលពីអាជីវកម្មរបស់ប្រជាពលរដ្ឋម្នាក់ៗអាចមានទាបជាងចំណូលពីសកម្មភាពផ្សេងក៏ដោយ។ ដូច្នេះ ត្រូវវិភាគស្ថានភាពអាជីវកម្មជាក់ស្តែងក្នុងក្រុង ដោយពិនិត្យពីកត្តាអ្វីខ្លះដែលបានជំរុញ និងអ្វីខ្លះជាឧបសគ្គដល់ការឈានឡើង ទាំងចំពោះមុខ និងយូរអង្វែងរបស់វិស័យអាជីវកម្មក្នុងក្រុង ហើយដែលកំពុងជះឥទ្ធិពលលើកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ពិសេសអាជីវករក្នុងក្រុង។ ទន្ទឹមនេះ ត្រូវបរិយាយពីអ្វីខ្លះដែលនាំឱ្យមានការផ្លាស់ប្តូរក្នុងមុខរបរជំនួញ (ឧទាហរណ៍ កត្តាសេដ្ឋកិច្ច ប្រែប្រួល) ហើយអ្វីខ្លះដែលក្រុងត្រូវធ្វើការព្យាយាមទប់ស្កាត់ ឬគ្រប់គ្រងការផ្លាស់ប្តូរទាំងនេះ ដើម្បីធានានិរន្តរភាព និងភាពរីកចម្រើនក្នុងវិស័យអាជីវកម្មនេះ។

ចំពោះស្រុកដែលមានប្រជាពលរដ្ឋភាគច្រើនប្រកបរបរធ្វើស្រែ នោះសកម្មភាពសេដ្ឋកិច្ចចម្បង សម្រាប់ស្រុក គឺកសិកម្ម ទោះបីជាចំណូលបានមកពីធ្វើស្រែរបស់ប្រជាកសិករម្នាក់ៗ អាចមានទាបជាងចំណូលពីសកម្មភាពផ្សេងក៏ដោយ។ ការរៀបរាប់អំពីស្ថានភាពសេដ្ឋកិច្ចរបស់ស្រុក ដែលមានសកម្មភាពសេដ្ឋកិច្ចចម្បងជាកសិកម្មមានលក្ខណៈ ដូចគ្នានឹងការរៀបរាប់ស្ថានភាពសេដ្ឋកិច្ចរបស់ក្រុងដូចមានរៀបរាប់ខាងលើ។

សកម្មភាពចម្បងក្នុងផ្នែកសេដ្ឋកិច្ចរួមមាន ÷

**អាជីវកម្ម** ÷ មុខរបបរសំខាន់ៗក្នុងវិស័យអាជីវកម្មរួមមាន មុខរបរជំនួញ ប្រភេទសិប្បកម្មនានា ជាងជួសជុល ។ល។ ក្នុងស្ថានភាពអាជីវកម្ម ត្រូវសរសេររៀបរាប់អំពីសក្តានុពលសំខាន់ៗរបស់ក្រុង ស្រុក ខណ្ឌ និងបញ្ហាប្រឈមនានាដែលក្រុង ស្រុក ខណ្ឌកំពុងជួបប្រទះ។

**កសិកម្ម ÷** សកម្មភាពសំខាន់ៗក្នុងវិស័យកសិកម្មរួមមាន ការដាំដុះស្រូវ ដំណាំកសិ-ឧស្សាហកម្ម និងដំណាំរួមផ្សំ ការចិញ្ចឹមសត្វនិងត្រី ការប្រើប្រាស់ដីធ្លី និងប្រព័ន្ធធារាសាស្រ្តដែលជួយគាំទ្រដល់ការងារកសិកម្ម។ ក្នុងស្ថានភាពកសិកម្ម ត្រូវសរសេររៀបរាប់អំពីសក្តានុពលសំខាន់ៗរបស់ក្រុង ស្រុក ខណ្ឌ និងបញ្ហាប្រឈមនានាដែលក្រុង ស្រុក ខណ្ឌកំពុងជួបប្រទះ។

**ឧស្សាហកម្ម ÷** សកម្មភាពសំខាន់ៗក្នុងវិស័យឧស្សហកម្មរួមមាន សកម្មភាពសិប្បកម្ម រោងចក្រ និងការងារសំណង់ជាដើម ។ល។ ដូច្នេះ ត្រូវសរសេររៀបរាប់អំពីសក្តានុពល និងបញ្ហាប្រឈមសំខាន់ៗដែលពាក់ព័ន្ធនឹងវិស័យនេះ។

**គមនាគមន៍ ÷** សរសេររៀបរាប់អំពីសក្តានុពលនៃប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធផ្លូវគោក និងផ្លូវទឹកក្នុងក្រុង ស្រុក ខណ្ឌមាន និងបញ្ហាប្រឈមសំខាន់ៗដែលក្រុង ស្រុក ខណ្ឌកំពុងជួបប្រទះ។

**សេវាកម្ម ÷** សរសេររៀបរាប់អំពីសក្តានុពល និងបញ្ហាប្រឈមនៃសេវាកម្មនានាពាក់ព័ន្ធនឹងពាណិជ្ជកម្ម សាធារណការ ទឹកស្អាត អគ្គិសនី ទីផ្សារ ទេសចរណ៍ និងសេវាឯកជនផ្សេងទៀត។

**ការវិនិយោគ ÷** ចំណុចនេះត្រូវសរសេររៀបរាប់អំពីទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងវិស័យឯកជន ជាមួយក្រុង ស្រុក ខណ្ឌ ដើម្បីរៀបចំគម្រោងអភិវឌ្ឍន៍នានានៅក្នុងក្រុង ស្រុក ខណ្ឌ ដូចជា ការអភិវឌ្ឍន៍ផ្សារ ចំណតរថយន្ត ផ្លូវ ស្ពាន និងគម្រោងអភិវឌ្ឍន៍ផ្សេងទៀត។ ដូច្នេះ ត្រូវសរសេររៀបរាប់អំពីសក្តានុពល និងបញ្ហាប្រឈមសំខាន់ៗដែលពាក់ព័ន្ធនឹងការវិនិយោគនេះ។

ក្រៅពីចំណុចសំខាន់ដែលបានរៀបរាប់ខាងលើ ក្រុង ស្រុក ខណ្ឌអាចបន្ថែមនូវចំណុចផ្សេងទៀត ដែលក្រុង ស្រុក ខណ្ឌយល់ថាចាំបាច់ និងគួរបញ្ចូលក្នុងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ។ ការសរសេររៀបរាប់ចំណុចបន្ថែមនេះ គឺដូចគ្នានឹងចំណុចនានាខាងលើដោយផ្តោតលើសក្តានុពល និងបញ្ហាប្រឈមនានា។

### ១.២.២. ស្ថានភាពសង្គមកិច្ច

ស្ថានភាពសង្គមកិច្ច ជាផ្នែកមួយដែលត្រូវធ្វើការសិក្សាពីលក្ខណៈប្រជាសាស្រ្ត សេវាសាធារណៈផ្នែកសង្គម និងសុវត្ថិភាពរបស់ប្រជាពលរដ្ឋនៅក្នុងក្រុង ស្រុក ខណ្ឌ ដូចជា ស្ថានភាពអប់រំ សុខមាលភាព យេនឌ័រ ភាពក្រីក្រ អំពើហិង្សា ការជួញដូរស្រ្តីនិងកុមារ ការលើកកម្ពស់សិទ្ធិមនុស្ស និងស្ថានភាពសាសនាជាដើម។ ការសរសេរអំពីស្ថានភាពសង្គមកិច្ច ត្រូវសរសេរជាលក្ខណៈវិភាគដោយផ្អែកលើលទ្ធផលនៃការវិភាគសង្គមកិច្ច និងត្រូវផ្តោតលើចំណុចសំខាន់ៗ មួយចំនួនដូចខាងក្រោម ៖

**ស្ថានភាពអប់រំ ÷** សរសេរពីការសម្រេចបានរបស់វិស័យអប់រំ ដូចជា ការសិក្សារបស់កុមារ ស្តង់ដារអប់រំ (ការចូលរៀនរបស់កុមារនៅថ្នាក់មត្តេយ្យ បឋមសិក្សា អនុវិទ្យាល័យ ការបោះបង់ចោលការសិក្សា ការរៀនត្រួតថ្នាក់ ពិសេសក្មេងស្រី ការងារអក្ខរកម្ម...)។

**ស្ថានភាពសុខាភិបាល ÷** សរសេរពីស្ថានភាពសុខភាពរបស់ប្រជាជន ពិសេសស្រ្តីនិងកុមារ កម្រិតទទួលបានសេវាសុខភាព អត្រាមរណភាពមាតានិងទារក គ្រោះថ្នាក់កើតពីជំងឺផ្សេងៗ (សុខភាពមាតានិងកុមារ ទឹកស្អាត អនាម័យ បញ្ហាយុវវ័យ សុខភាព បន្តពូជ...)។

**ស្ថានភាពយេនឌ័រ ÷** សរសេរពីការទទួលយកសេវា ការសម្រេចចិត្ត ការចូលរួមចំណែកក្នុងសង្គមរបស់ស្រ្តី ការលំបាកដែលស្រ្តីកំពុងជួបប្រទះ(បុរសពុំបានជួប) ឬកត្តាទាំងឡាយក្នុងសង្គមដែលនាំឱ្យស្រ្តីជួបការលំបាកញឹកញាប់ជាងបុរស។

**ស្ថានភាពនៃភាពក្រីក្រ ÷** សរសេរពីកម្រិតភាពក្រីក្ររបស់ប្រជាជនក្នុងក្រុង ស្រុក ខណ្ឌ ដោយបង្ហាញពីបណ្តាមូលហេតុចម្បងៗដែលនាំឱ្យមានគ្រួសារមួយចំនួនធ្លាក់ខ្លួនក្រ មូលហេតុដែលគ្រួសារក្រីក្រមិនអាចកែលម្អជីវភាពរបស់ពួកគេបាន និងមូលហេតុដែលគ្រួសារក្រីក្របានកែលម្អជីវភាពខ្លួន ។

**ស្ថានភាពសាសនា ÷** រៀបរាប់ជាព័ត៌មានអំពីសាសនានានាដែលមានក្នុងក្រុង ស្រុក ខណ្ឌ និងចំនួនភាគរយប្រជាពលរដ្ឋដែលកាន់សាសនានីមួយៗ ។

**ស្ថានភាពអន្តោប្រវេសន៍ និងបំលាស់ទី ÷** ចំណុចនេះ ត្រូវសរសេររៀបរាប់អំពីស្ថានភាពនៃការបំលាស់ទីរបស់ប្រជាពលរដ្ឋពីតំបន់នានាចូលមកក្រុង ស្រុក ខណ្ឌ ដើម្បីប្រកបមុខរបរផ្សេងៗ ដូចជា ប្រកបមុខរបរជាកម្មករ រត់ម៉ូតូឌុប កម្មកររោងចក្រ... និងជនបរទេសដែលចូលមកក្រុង ស្រុក ខណ្ឌ ជាអ្នកទេសចរណ៍ ឬមកប្រកបមុខរបរផ្សេងៗ។ ដូច្នេះ ចំណុចនេះត្រូវសរសេររៀបរាប់អំពីសក្តានុពល និងបញ្ហាប្រឈមសំខាន់ៗដែលពាក់ព័ន្ធនឹងស្ថានភាពទាំងនេះ ។

ក្រៅពីស្ថានភាពសំខាន់ៗខាងលើ ក្រុង ស្រុក ខណ្ឌ អាចធ្វើការរៀបរាប់បន្ថែមអំពីស្ថានភាពផ្សេងទៀតដែលពាក់ព័ន្ធនឹងស្ថានភាពសង្គមកិច្ច ផ្អែកតាមស្ថានភាពជាក់ស្តែងរបស់ក្រុង ស្រុក ខណ្ឌនីមួយៗ ដូចជា ការលើកកម្ពស់សិទ្ធិកុមារ និងប្រជាពលរដ្ឋទូទៅ ការទប់ស្កាត់សកម្មភាពជួញដូរស្ត្រីនិងកុមារ ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការជួយជនចាស់ជរាគ្មានទីពឹង និរត្តន៍ជន កុមារកំព្រា ជនអនាថា ។ល ។

### ១.២.៣. ស្ថានភាពនៃការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន

ផ្អែកតាមស្ថានភាពជាក់ស្តែងរបស់ក្រុង ស្រុក ខណ្ឌ ក្នុងចំណុចនេះត្រូវសរសេររៀបរាប់អំពីអ្វីខ្លះដែលជាភាពខ្លាំង (សក្តានុពល) និងផលប្រយោជន៍ដែលក្រុង ស្រុក ខណ្ឌមាន និងទទួលបានដីធ្លី និងធនធានធម្មជាតិ និងអ្វីខ្លះដែលជាបញ្ហាប្រឈម ឬឧបសគ្គដែលកំពុងគំរាមកំហែងដល់ដីធ្លី ធនធានធម្មជាតិ និងបរិស្ថាន។ ការសរសេរផ្នែកនេះត្រូវផ្អែកលើលទ្ធផលនៃការវិភាគការប្រើប្រាស់ដីធ្លី ការវិភាគធនធានធម្មជាតិ និងការវិភាគបរិស្ថាន ដោយផ្តោតលើ ៖

- **ការប្រើប្រាស់ដីធ្លី ÷** ប្រភេទសំខាន់ៗនៃការប្រើប្រាស់ដីធ្លី (ដីលំនៅដ្ឋាន ដីធ្វើស្រែ ដីចំការ ដីសម្រាប់ការវិនិយោគ ដីសម្បទាន តំបន់អភិរក្ស...ជាដើម) និងបញ្ហាប្រឈមសំខាន់ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ដីធ្លីនេះ។ ជាពិសេសចំពោះ ការប្រើប្រាស់ដីធ្លីសម្រាប់លំនៅដ្ឋាន ត្រូវរៀបរាប់អំពីសក្តានុពល និងបញ្ហាប្រឈមពាក់ព័ន្ធនឹងការកំណត់ប្រភេទលំនៅដ្ឋាន ការផ្លាស់ប្តូរទីតាំង ការរៀបចំនិងគ្រប់គ្រងសំណង់អាណាធិបតេយ្យ និងការរៀបចំប្លង់លំនៅដ្ឋានជាដើម ។ល ។
- **ធនធានធម្មជាតិ ÷** (ដីធ្លី ព្រៃឈើ សត្វព្រៃ ធនធានជលផល បឹង អូរ ស្ទឹង រ៉ែ... ។ល ។)សំខាន់ៗ ដែលប្រជាជនពឹងផ្អែកលើធនធានទាំងនេះសម្រាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគាត់ ។ ដូច្នេះ ត្រូវសរសេរពីកម្រិតនៃការប្រើប្រាស់ធនធានទាំងនេះ និងបញ្ហាប្រឈមសំខាន់ៗដែលកំពុងជួបប្រទះពាក់ព័ន្ធនឹងការប្រើប្រាស់នេះ ។
- **បរិស្ថាន ÷** ចំណុចនេះ ត្រូវសរសេររៀបរាប់អំពីសក្តានុពលរបស់ក្រុង ស្រុក ខណ្ឌពាក់ព័ន្ធនឹងបរិស្ថាន ដូចជាការរៀបចំឱ្យមានកន្លែងលំហាត់ប្រាណ និងសួនឧទ្យានសាធារណៈ និងបញ្ហានានា ដែលគំរាមកំហែងលើបរិស្ថាន ដូចជាការបំពុលបរិយាកាស កាកសំណល់រឹង និងរាវ ។ល ។

### ១.២.៤. ស្ថានភាពនៃការគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ

ផ្នែកនេះ ត្រូវសរសេររៀបរាប់អំពីគ្រោះថ្នាក់ ការបាត់បង់ខូចខាត ការបំផ្លិចបំផ្លាញ ការប្រែប្រួល និងផលប៉ះពាល់ជាអវិជ្ជមានទាំងឡាយដែលកើតមានឡើងនៅក្នុងក្រុង ស្រុក ខណ្ឌដោយមនុស្សជាអ្នកបង្កឡើង ឬដោយធម្មជាតិ។ ការសរសេរផ្នែកនេះ ត្រូវផ្អែកលើលទ្ធផលនៃការវិភាគគ្រោះមហន្តរាយ និងការវិភាគបរិស្ថាន។

- **គ្រោះមហន្តរាយសំខាន់ៗ ៖** ការបំផ្លិចបំផ្លាញដោយសារខ្យល់ព្យុះ ភ្លើងឆេះផ្ទះ គ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ គ្រោះទឹកជំនន់ជាដើម។
- **ការប្រែប្រួលអាកាសធាតុ ៖** ទឹកជំនន់ ភាពរាំងស្ងួត សីតុណ្ហភាពឡើងខ្ពស់ កម្រិតទឹកភ្លៀងមិនគ្រប់គ្រាន់ ភ្លៀងធ្លាក់ខុសរដូវ ឬច្រើនពេក...។

### ១.២.៥. ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងការសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

ផ្នែកនេះ ត្រូវសរសេររៀបរាប់ដោយសង្ខេបអំពីចំណុចសំខាន់ៗមួយចំនួន ដូចជា អភិបាលកិច្ច ការគ្រប់គ្រងដែនដី ស្ថិតិប្រជាជន កិច្ចការសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ដោយផ្អែកលើលទ្ធផលនៃការវិភាគស្ថានភាពរដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។ ទិន្នន័យ និងព័ត៌មានមួយចំនួនដែលត្រូវរៀបរាប់ក្នុងផ្នែកនេះ មានបង្ហាញនៅក្នុងតារាងអំពីព័ត៌មានសំខាន់ៗរបស់ក្រុង ស្រុក ខណ្ឌ ដូចជា ផ្ទៃដីក្រុង ស្រុក ខណ្ឌ ចំនួនឃុំ សង្កាត់ និងស្ថិតិប្រជាជនជាដើម។

- **អភិបាលកិច្ច ៖** ភាពខ្លាំង និងបញ្ហាប្រឈមពាក់ព័ន្ធនឹងអភិបាលកិច្ចនៅក្រុង ស្រុក ខណ្ឌ
- **ការគ្រប់គ្រងដែនដី ៖** ភាពខ្លាំង និងបញ្ហាប្រឈមពាក់ព័ន្ធនឹងការរៀបចំ និងគ្រប់គ្រងដែនដី រដ្ឋបាល ដូចជា ការកំណត់ព្រំប្រទល់ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ និងតំបន់សំខាន់ៗក្នុងក្រុង ស្រុក ខណ្ឌ ការបង្កើតភូមិថ្មី ការរៀបចំប្លង់គោលជាដើម
- **ការគ្រប់គ្រងស្ថិតិ ៖** បញ្ហាសំខាន់ៗពាក់ព័ន្ធនឹងការចុះបញ្ជី និងការងារអត្រានុកូលដ្ឋាន
- **ការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ៖** ភាពខ្លាំង និងបញ្ហាសំខាន់ៗពាក់ព័ន្ធនឹងការគ្រប់គ្រង និងការរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈក្នុងក្រុង ស្រុក ខណ្ឌ និងតំបន់ទីប្រជុំជនសំខាន់ៗផ្សេងទៀត។
- **ចំពោះក្រុង ស្រុកដែលមានព្រំដែនជាប់ជាមួយប្រទេសជិតខាងគួរបញ្ចូលព័ត៌មានអំពីការងារព្រំដែន ៖** ភាពងាយស្រួល និងការលំបាកក្នុងការរៀបចំ និងគ្រប់គ្រងច្រកព្រំដែន និងកិច្ចសហការជាមួយប្រទេសជិតខាង។

## ជំពូកទី២ ៖ ក្របខ័ណ្ឌអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ

នេះជាជំពូកសំខាន់របស់ផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌដែលត្រូវសរសេរ ដោយផ្អែកលើការពិចារណា និងឱ្យតម្លៃសមស្របមានភាពគ្រប់ជ្រុងជ្រោយ ផ្អែកលើសក្តានុពល ឧបសគ្គ ឬបញ្ហាប្រឈមដែលបានរកឃើញនៅក្នុងការវិភាគស្ថានភាពក្រុង ស្រុក ខណ្ឌ។ ការសរសេរក្របខ័ណ្ឌអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ត្រូវផ្អែកលើលទ្ធផលនៃការវិភាគស្ថានភាពក្នុងជំពូកទី១ខាងលើ។

### ២.១. ចក្ខុវិស័យអភិវឌ្ឍន៍

ចក្ខុវិស័យអភិវឌ្ឍន៍ គឺជាអ្វីដែលក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចង់សម្រេចបានជាចម្បងក្នុងការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌរបស់ខ្លួន។

ការសរសេរអំពីចក្ខុវិស័យ មិនត្រូវមានមហិច្ឆតាខ្ពស់ហួសពីសមត្ថភាព លទ្ធភាព ដែលនាំឱ្យអនុវត្តមិនបាន ប៉ុន្តែក៏មិនគួរសរសេរមានលក្ខណៈងាយអនុវត្តពេក ដែលនាំឱ្យបាត់ភាពខិតខំប្រឹងប្រែង ខ្ជះខ្ជាយ ពេលវេលា និងធនធាននានានៅពេលអនុវត្ត។ ក្នុងចក្ខុវិស័យអភិវឌ្ឍន៍ ត្រូវមានខ្លឹមសារដែលក្រុង ស្រុក ខណ្ឌចង់បានក្នុងការកែលម្អស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច អភិបាលកិច្ច ផ្អែកតាមតម្រូវការអភិវឌ្ឍន៍ជាក់ស្តែងរបស់ក្រុង ស្រុក ខណ្ឌ។

ការសរសេរចក្ខុវិស័យអភិវឌ្ឍន៍ ត្រូវផ្អែកលើក្របខ័ណ្ឌអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ដែលបានរៀបចំក្នុងជំហានទី៣នៃការកសាងផែនការអភិវឌ្ឍន៍។

## ២.២. គោលដៅអភិវឌ្ឍន៍

គោលដៅអភិវឌ្ឍន៍ គឺជាការបរិយាយពីលទ្ធផលរួមដែលក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌរំពឹងថានឹងសម្រេចឱ្យបានតាមរយៈការអនុវត្តផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំរបស់ក្រុង ស្រុក ខណ្ឌដែលរួមចំណែកក្នុងការសម្រេចបាននូវចក្ខុវិស័យអភិវឌ្ឍន៍របស់ក្រុង ស្រុក ខណ្ឌ។

ការសរសេរគោលដៅអភិវឌ្ឍន៍ ត្រូវយោងតាមខ្លឹមសាររបស់ចក្ខុវិស័យអភិវឌ្ឍន៍ ដែលបានសរសេរក្នុងចំណុច ២.១ខាងលើ។ ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌគួរកំណត់យកគោលដៅអភិវឌ្ឍន៍មូលដ្ឋានខ្លួនឱ្យបានសមស្រប ដោយថ្លឹងថ្លែងពីតុល្យភាពរវាងទំហំនៃគោលបំណងដែលបានកំណត់។ គោលដៅគួរសរសេរតាមផ្នែកទាំងបួន (ផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ច ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ និងផ្នែករដ្ឋបាលនិងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ)។ ការសរសេរអំពីគោលដៅអភិវឌ្ឍន៍នេះ ក៏ត្រូវធ្វើការថ្លឹងថ្លែងជាមួយនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា និងគោលនយោបាយជាតិផងដែរ។

## ២.៣. គោលបំណងអភិវឌ្ឍន៍

គោលបំណងអភិវឌ្ឍន៍ គឺជាការបរិយាយអំពីលទ្ធផលនានាដែលក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ រំពឹងថានឹងសម្រេចបានតាមវិស័យនីមួយៗ តាមរយៈការអនុវត្តផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរបស់ក្រុង ស្រុក ខណ្ឌ ដែលរួមចំណែកក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍របស់ក្រុង ស្រុក ខណ្ឌ។

គោលបំណងអភិវឌ្ឍន៍ ត្រូវមានលក្ខណៈជាក់លាក់ដែលអាចវាស់វែងបាន អាចសម្រេចបានក្នុងរយៈពេលកំណត់មួយ និងឆ្លើយតបទៅគោលដៅអភិវឌ្ឍន៍។ គោលបំណងអភិវឌ្ឍន៍ត្រូវសរសេរតាមវិស័យនីមួយៗក្នុងផ្នែកទាំងបួន។ គោលបំណងនីមួយៗ ត្រូវមានការកំណត់សូចនាករឱ្យបានជាក់លាក់ដោយផ្អែកលើសូចនាករនៃកម្រងឯកសារព័ត៌មានក្រុង ស្រុក ខណ្ឌ និងត្រូវធ្វើការថ្លឹងថ្លែងជាមួយនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជាផងដែរ។

## ២.៤. យុទ្ធសាស្ត្រអភិវឌ្ឍន៍

បន្ទាប់ពីការកំណត់គោលបំណងអភិវឌ្ឍន៍ ក្រុមការងារកសាងផែនការក្រុង ស្រុក ខណ្ឌ ត្រូវកំណត់យុទ្ធសាស្ត្រអភិវឌ្ឍន៍ដែលជាមធ្យោបាយ ឬវិធីសាស្ត្រ ដើម្បីសម្រេចគោលបំណងនីមួយៗ។ លក្ខណៈវិនិច្ឆ័យក្នុងការកំណត់យុទ្ធសាស្ត្ររួមមានធនធាន និងតម្រូវការជាអាទិភាពនានារបស់ក្រុង ស្រុក ខណ្ឌ។

ការកំណត់យុទ្ធសាស្ត្រអភិវឌ្ឍន៍ ត្រូវផ្អែកលើគោលបំណងអភិវឌ្ឍន៍ និងដំណោះស្រាយជាអាទិភាព ដែលបានកំណត់ក្នុងតារាងតម្រូវការជាអាទិភាពរបស់ក្រុង ស្រុក ខណ្ឌ។ បន្ទាប់មក ក្រុមការងារកសាងផែនការត្រូវធ្វើការបូកសរុបបញ្ចូលទៅក្នុងតារាងក្របខ័ណ្ឌអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌខាងក្រោម។

**តារាងក្របខ័ណ្ឌអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ**

| ចក្ខុវិស័យ ៖ | | | | |
|---|---|---|---|---|
| គោលដៅ និងគោលបំណង | សូចនាករ | | | យុទ្ធសាស្ត្រអភិវឌ្ឍន៍ |
| | ឯកតា | ២០០៩ | ២០១៤ | |
| **១. ផ្នែកសេដ្ឋកិច្ច** | | | | |
| ១.១. គោលដៅ ៖ | | | | |
| ១.១.១. គោលបំណង ៖ | | | | |
| ១.១.២. គោលបំណង ៖ | | | | |
| ១.២. គោលដៅ ៖ | | | | |
| ១.២.១. គោលបំណង ៖ | | | | |
| ១.២.២. គោលបំណង ៖ | | | | |
| **២. ផ្នែកសង្គមកិច្ច** | | | | |
| ២.១. គោលដៅ ៖ | | | | |
| ២.១.១. គោលបំណង ៖ | | | | |
| ២.១.២. គោលបំណង ៖ | | | | |
| **៣. ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ** | | | | |
| ៣.១. គោលដៅ ៖ | | | | |
| ៣.១.១. គោលបំណង ៖ | | | | |
| ៣.១.២. គោលបំណង ៖ | | | | |
| **៤. ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** | | | | |
| ៤.១. គោលដៅ ៖ | | | | |
| ៤.១.១. គោលបំណង ៖ | | | | |
| ៤.១.២. គោលបំណង ៖ | | | | |

### ២.៤.១. យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច

ការអភិវឌ្ឍន៍សេដ្ឋកិច្ច គឺជាបង្គោលគ្រឹះមួយក្នុងចំណោមបង្គោលគ្រឹះនានានៃការអភិវឌ្ឍន៍សង្គម។ ដូច្នេះ ក្នុងចំណុចនេះ ត្រូវបរិយាយពីបណ្តាវិស័យស្នូលក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ក្រុង ស្រុក ខណ្ឌ ដោយត្រូវយកចិត្តទុកដាក់ពិចារណាពីលទ្ធភាព កម្រិតនិរន្តរភាពនៃសក្តានុពលសេដ្ឋកិច្ចរបស់វិស័យពាក់ព័ន្ធក្នុងការអភិវឌ្ឍក្រុង ស្រុក ខណ្ឌ។ ការសរសេរយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច ត្រូវផ្អែកលើយុទ្ធសាស្ត្រអភិវឌ្ឍន៍នានាដែលបានកំណត់សម្រាប់ផ្នែកសេដ្ឋកិច្ចនៅក្នុងតារាងក្របខ័ណ្ឌអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ និងត្រូវថ្លឹងថ្លែងជាមួយនឹងស្ថានភាពសេដ្ឋកិច្ចដែលបានរៀបរាប់ក្នុងជំពូកទី១។

### ២.៤.២. យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច

ការអភិវឌ្ឍន៍សង្គមកិច្ច ក៏ជាបង្គោលគ្រឹះមួយដ៏សំខាន់ក្នុងចំណោមបង្គោលគ្រឹះនានានៃការអភិវឌ្ឍន៍សង្គម។ ក្នុងចំណុចនេះ ត្រូវបរិយាយពីបណ្តាការងារសង្គមកិច្ចដែលចង់បាន ដើម្បីរួមចំណែកក្នុងដំណើរការអភិវឌ្ឍន៍មូលដ្ឋាន។ ការសរសេរនេះ ត្រូវបរិយាយអំពីផ្នែករឹង(ផ្នែករូបវន្ត) និងផ្នែកទន់(ផ្នែកអរូបវន្ត) ទាំងចំពោះមុខ និងនិន្នាការតទៅថ្ងៃមុខ។ ផ្នែកនេះត្រូវសរសេរដោយផ្អែកយុទ្ធសាស្ត្រអភិវឌ្ឍន៍ ដែលបានកំណត់សម្រាប់ផ្នែកសង្គមកិច្ច ដូចមាននៅក្នុងតារាងក្របខ័ណ្ឌអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ និងត្រូវថ្លឹងថ្លែងជាមួយនឹងស្ថានភាពសង្គមកិច្ចដែលបានរៀបរាប់ក្នុងជំពូកទី១។

### ២.៤.៣. យុទ្ធសាស្ត្រប្រើប្រាស់ដីធ្លី និងគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន

ដីធ្លី ធនធានធម្មជាតិ និងបរិស្ថាន ជាកត្តាពុំអាចខ្វះបានក្នុងសកម្មភាពអភិវឌ្ឍន៍។ និរន្តរភាពក្នុងការអភិវឌ្ឍន៍ គឺអាស្រ័យទៅនឹងភាពគង់វង្សនៃសក្តានុពល ការប្រើប្រាស់ និងការគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ និងបរិស្ថាន និងសមត្ថភាពរបស់មនុស្ស។ ដូច្នេះ ក្នុងចំណុចនេះ ត្រូវបរិយាយអំពីការគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ធនធានធម្មជាតិ និងបរិស្ថាន ផ្អែកលើស្ថានភាពដែលបានលើកឡើងក្នុងជំពូកទី១។ ក្នុងយុទ្ធសាស្ត្រប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ត្រូវធ្វើការរៀបរាប់ដូចជាតំបន់(ដី) ដែលត្រូវប្រើប្រាស់សម្រាប់លំនៅដ្ឋាន ដីសម្រាប់រៀបចំតំបន់អភិវឌ្ឍន៍ ដីសម្រាប់គ្រប់គ្រងប្រើប្រាស់ដោយសហគមន៍នានា មូលដ្ឋានគតិយុត្តដែលកំណត់តំបន់សម្រាប់ផ្លាស់ប្តូរគោលបំណងប្រើប្រាស់ ការអភិរក្ស និងភ្ជាប់ជាមួយនូវផែនទីប្រើប្រាស់ដីធ្លី(បើមាន)។ ជាមួយនេះ ត្រូវសរសេរពីតួនាទី និងការទទួលខុសត្រូវរបស់អង្គភាពពាក់ព័ន្ធក្នុងការគ្រប់គ្រងប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និង បរិស្ថានក្នុងក្រុង ស្រុក ខណ្ឌ។ ការសរសេររៀបរាប់អំពីចំណុចខាងលើនេះ ត្រូវផ្អែកលើយុទ្ធសាស្ត្រអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌដែលបានកំណត់នៅក្នុងតារាងក្របខ័ណ្ឌអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ និងត្រូវធ្វើការថ្លឹងថ្លែងជាមួយនឹងស្ថានភាពនៃការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានដែលបានរៀបរាប់ក្នុងជំពូកទី១។

### ២.៤.៤. យុទ្ធសាស្ត្រគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ

ផ្អែកលើស្ថានភាពគ្រោះមហន្តរាយ និងប្រែប្រួលអាកាសធាតុដែលបានរៀបរាប់នៅក្នុងជំពូកទី១ ត្រូវបរិយាយអំពីយុទ្ធសាស្ត្រសំខាន់ៗ សម្រាប់គ្រប់គ្រង និងកាត់បន្ថយគ្រោះភ័យ គ្រោះថ្នាក់ ការបំផ្លិចបំផ្លាញនានាបណ្តាលមកពីគ្រោះមហន្តរាយ និងការផ្លាស់ប្តូរ ឬឥទ្ធិពលជាអវិជ្ជមានដែលបាន និងឬអាចកើតមានឡើងដោយធម្មជាតិ និងឬដោយការធ្វេសប្រហែសរបស់មនុស្ស។ ជាមួយនេះដែរ ត្រូវសរសេរពីតួនាទី និងការទទួលខុសត្រូវរបស់អង្គភាពពាក់ព័ន្ធក្នុងការ

គ្រប់គ្រងគ្រោះមហន្តរាយ និងការសម្របសម្រួលជាមួយនឹងការប្រែប្រួលអាកាសធាតុនៅក្នុងក្រុង ស្រុក ខណ្ឌ និងធនធានដែលត្រូវការសម្រាប់ត្រៀមបង្ការ និងកាត់បន្ថយគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុនានា។

### ២.៤.៥. យុទ្ធសាស្ត្រគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

ផ្អែកលើស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈដែលបានរៀបរាប់នៅក្នុងជំពូកទី១ ផ្នែកនេះត្រូវបរិយាយអំពីយុទ្ធសាស្ត្រសំខាន់ៗសម្រាប់ការគ្រប់គ្រងដែនដីរដ្ឋបាល ដូចជា ការកំណត់ព្រំប្រទល់ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិឱ្យបានច្បាស់លាស់ ការពង្រឹងការគ្រប់គ្រង និងថែរក្សាប្រព័ន្ធទិន្នន័យ និងព័ត៌មានអំពីស្ថិតិប្រជាជន និងព័ត៌មានចាំបាច់ផ្សេងទៀត វិធានការលើកកម្ពស់សន្តិសុខ ការរៀបចំ និងការថែរក្សាសោភ័ណភាពបរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈក្នុងក្រុង ស្រុក ខណ្ឌ។

## ២.៥. ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម

ផ្អែកតាមទំហំនៃសូចនាករអភិវឌ្ឍន៍ដែលបានសរសេរខាងលើ ត្រូវធ្វើការគណនាប៉ាន់ស្មានអំពីតម្រូវការថវិកាចំណាយ។ ថវិកាចំណាយមានពីរផ្នែក គឺផ្នែកចំណាយចរន្ត និងផ្នែកចំណាយមូលធន។ ទោះបីជាថវិកាចំណាយនេះ មិនទាន់មានលក្ខណៈត្រឹមត្រូវឥតខ្ចោះក៏ដោយ ក៏ថវិកាចំណាយនេះ បង្ហាញឱ្យឃើញពីភាពម្ចាស់ការក្នុងកម្រិតណាមួយរបស់ក្រុង ស្រុក ខណ្ឌ នៅពេលបំប្លែងសូចនាករអភិវឌ្ឍន៍៥ឆ្នាំ ទៅជាទំហំនៃគម្រោងការងារ ឬសកម្មភាពអភិវឌ្ឍន៍ប្រចាំឆ្នាំ។ សេចក្តីណែនាំលម្អិតសម្រាប់រៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនឹងធ្វើការណែនាំជាក្រោយ។

# ជំពូកទី៣

# ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ និងសមិទ្ធផលនៃការងារនានាជាកិច្ចការចាំបាច់ និងមានសារៈសំខាន់ពុំអាចរំលងបានសម្រាប់ការងារគ្រប់គ្រងរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ។ ការតាមដាន គឺត្រូវធ្វើឡើងដើម្បីជំរុញឱ្យការងារអនុវត្តបានប្រព្រឹត្តទៅដល់គោលដៅអភិវឌ្ឍន៍ដែលបានកំណត់ ហើយក៏ដើម្បីមានការសម្រេចចិត្ត (ផ្តល់ការលើកទឹកចិត្ត ឬកែតម្រូវជាចាំបាច់) ត្រង់ប្រការណាមួយដែលមិនសមស្រប។ ដូច្នេះក្នុងការសរសេរអំពីការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ត្រូវរៀបរាប់អំពី ៖ ផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃអនុវត្តផែនការអភិវឌ្ឍន៍ យន្តការ ប្រតិបត្តិករ វិធីសាស្ត្រធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ សូចនាករគោលបំណង សូចនាករដើមគ្រា និងពេលវេលាសម្រាប់ប្រតិបត្តិការ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការ។

### ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ គឺជាបណ្តុំឯកសារយោង សម្រាប់បង្កើនទម្ងន់នៃចំណុចពាក់ព័ន្ធណាមួយ។ ហេតុនេះ ការបញ្ចូលឯកសារឧបសម្ព័ន្ធក្នុងសៀវភៅផែនការអភិវឌ្ឍន៍ គឺអាស្រ័យតាមការសម្រេចចិត្តរបស់ក្រុង ស្រុក ខណ្ឌ។

ឯកសារដែលអាចបញ្ចូលជាឧបសម្ព័ន្ធរួមមាន ៖

- គោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សាអំពីការកសាងផែនការ

- រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- លទ្ធផលសំខាន់ៗនៃការវិភាគស្ថានភាពក្រុង ស្រុក ខណ្ឌ
- លិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការកសាងផែនការ
- ផែនទីសំខាន់ៗដូចជាផែនទីនៃការប្រើប្រាស់ដីធ្លី ផែនទីតំបន់ទេសចរណ៍ ។ល ។

## ៥. ដំណើរការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ

ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវធានាឱ្យបានថា ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់ខ្លួន ត្រូវបានដាក់បញ្ចូលនូវផែនការអភិវឌ្ឍន៍របស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអ្នកពាក់ព័ន្ធនានា ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។

ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ជាអ្នកទទួលខុសត្រូវក្នុងការរៀបចំ និងអនុម័តផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ ដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ តាមរយៈកម្មវិធីវិនិយោគបីឆ្នាំរំកិល ។ ដូច្នេះ ដំណើរការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ គឺស្ថិតក្រោមការដឹកនាំ និងគ្រប់គ្រងដោយក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។

ដំណើរការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌមាន៤ជំហាន ៖

- ជំហានទី១ ÷ ការត្រៀមរៀបចំសម្រាប់ការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ
- ជំហានទី២ ÷ ការផ្សព្វផ្សាយព័ត៌មានអំពីការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ
- ជំហានទី៣ ÷ ការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ
- ជំហានទី៤ ÷ ការអនុម័តផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ

## ជំហានទី១ ៖ ការត្រៀមរៀបចំសម្រាប់ការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ

### ១.១. គោលបំណង

គោលបំណងសំខាន់របស់ជំហាននេះ គឺការរៀបចំគោលការណ៍ណែនាំផ្តែកគោលនយោបាយរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ប្រតិទិនការងារសម្រាប់ការកសាងផែនការ ការណែនាំអំពីការបំពេញតារាងបញ្ហា និងតម្រូវការរបស់ឃុំ សង្កាត់ ការិយាល័យ អង្គភាព អង្គការសង្គមស៊ីវិល និងវិស័យឯកជននានាក្នុងក្រុង ស្រុក ខណ្ឌ និងរៀបចំទិន្នន័យ និងឯកសារនានាដែលពាក់ព័ន្ធនឹងការកសាងផែនការអភិវឌ្ឍន៍។

### ១.២. លទ្ធផលរំពឹងទុក

- គោលការណ៍ណែនាំផ្តែកគោលនយោបាយរបស់ក្រុមប្រឹក្សា ពាក់ព័ន្ធនឹងការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ត្រូវបានរៀបចំ និងអនុម័តដោយក្រុមប្រឹក្សា
- ប្រតិទិនការងារសម្រាប់ការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ត្រូវបានរៀបចំ និងអនុម័តដោយក្រុមប្រឹក្សា
- បញ្ជីបូកសរុបបញ្ហា និងតម្រូវការនានារបស់ឃុំ សង្កាត់ ការិយាល័យ អង្គភាព អង្គការសង្គមស៊ីវិល និងវិស័យឯកជននានាត្រូវបានរៀបចំ
- ទិន្នន័យ និងឯកសារនានាដែលត្រូវប្រើប្រាស់ក្នុងការរៀបចំផែនការ ត្រូវបានរៀបចំ។

### ១.៣. ដំណើរការ

១.៣.១. កិច្ចប្រជុំណែនាំ

**ក). សមាសភាពចូលរួម**

កិច្ចប្រជុំណែនាំត្រូវរៀបចំឡើងក្រោមការដឹកនាំ និងសម្របសម្រួលរបស់អភិបាលក្រុង ស្រុក ខណ្ឌ និងជាប្រធានក្រុមការការងារកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ។ សមាភាពចូលរួមក្នុងកិច្ចប្រជុំណែនាំរួមមាន ៖

- ក្រុមការងារកសាងផែនការក្រុង ស្រុក ខណ្ឌ
- តំណាងគណៈអភិបាលក្រុង ស្រុក ខណ្ឌ
- តំណាងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងតំណាងគណៈកម្មាធិការពាក់ព័ន្ធនានា
- មេឃុំ ចៅសង្កាត់នៅក្នុងក្រុង ស្រុក ខណ្ឌ
- តំណាងការិយាល័យ អង្គភាពនានាក្នុងក្រុង ស្រុក ខណ្ឌ
- តំណាងអង្គការសង្គមស៊ីវិលនានាក្នុងក្រុង ស្រុក ខណ្ឌ
- តំណាងវិស័យឯកជនសំខាន់ៗក្នុងក្រុង ស្រុក ខណ្ឌ
- អ្នកពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់។

## ៩). របៀបវារៈនៃកិច្ចប្រជុំ

ក្រុមការងារកសាងផែនការក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំ និងត្រៀមបង្ហាញណែនាំដល់ឃុំ សង្កាត់ ការិយាល័យ អង្គភាព អង្គការសង្គមស៊ីវិល និងវិស័យឯកជននានាក្នុងក្រុង ស្រុក ខណ្ឌ អំពីការរៀបចំតារាងបញ្ហា តម្រូវការ នៅពេលផ្សព្វផ្សាយ និងប្រើប្រាស់សម្រាប់ការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ។

របៀបវារៈសំខាន់ៗរបស់កិច្ចប្រជុំណែនាំរួមមាន ៖

- បទបង្ហាញដោយសង្ខេបពីដំណើរការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ និងតម្រូវការទិន្នន័យ និងព័ត៌មាននានាសម្រាប់ការសាងផែនការ
- ការបង្ហាញ និងណែនាំក្នុងការបំពេញតារាង ៖
  - តារាង១.១ ៖ បញ្ហា និងតម្រូវការជាអាទិភាពឃុំ សង្កាត់
  - តារាង១.២ ៖ បញ្ហា និងតម្រូវការជាអាទិភាពរបស់ការិយាល័យ អង្គភាព
  - តារាង១.៣ ៖ បញ្ហា និងតម្រូវការជាអាទិភាពរបស់អង្គការសង្គមស៊ីវិល
  - តារាង១.៤ ៖ ស្ថានភាពវិនិយោគរបស់វិស័យឯកជន
- កំណត់ពេលវេលាក្នុងការបញ្ជូនតារាងមកក្រុមការងារកសាងផែនការក្រុង ស្រុក ខណ្ឌ។

**គំរូតារាង១.១ ៖ បញ្ហា និងតម្រូវការជាអាទិភាពឃុំ សង្កាត់ ឆ្នាំ..........**

ឃុំ សង្កាត់............. ក្រុង ស្រុក ខណ្ឌ............... រាជធានី ខេត្ត................

| វិស័យ និងសកម្មភាព | បញ្ហា | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ | អាទិភាព |
|---|---|---|---|---|---|
| **១. ផ្នែកសេដ្ឋកិច្ច** | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| **២. ផ្នែកសង្គមកិច្ច** | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| **៣. ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ** | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| **៤. ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** | | | | | |
| | | | | | |
| | | | | | |
| | | | | | |

គំរូតារាង១.២ ៖ បញ្ហា និងតម្រូវការអាទិភាពរបស់ការិយាល័យ អង្គភាព ឆ្នាំ.......

ការិយាល័យ អង្គភាព......... ក្រុង ស្រុក ខណ្ឌ......... រាជធានី ខេត្ត..........

| វិស័យ និងសេវា | បញ្ហា | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ |
|---|---|---|---|---|
| **១. ផ្នែកសេដ្ឋកិច្ច** | | | | |
| | | | | |
| | | | | |
| | | | | |
| **២. ផ្នែកសង្គមកិច្ច** | | | | |
| | | | | |
| | | | | |
| | | | | |
| **៣. ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ** | | | | |
| | | | | |
| | | | | |
| | | | | |
| **៤. ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** | | | | |
| | | | | |
| | | | | |
| | | | | |

គំរូតារាង១.៣ ៖ បញ្ហា និងតម្រូវការអាទិភាពរបស់អង្គការសង្គមស៊ីវិល ឆ្នាំ.......

អង្គការ........................

| វិស័យ និងសេវា | បញ្ហា | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ |
|---|---|---|---|---|
| **១. ផ្នែកសេដ្ឋកិច្ច** | | | | |
| | | | | |
| | | | | |
| | | | | |
| **២. ផ្នែកសង្គមកិច្ច** | | | | |
| | | | | |
| | | | | |
| | | | | |
| **៣. ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ** | | | | |
| | | | | |
| | | | | |
| | | | | |
| **៤. ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** | | | | |
| | | | | |
| | | | | |
| | | | | |

**គំរូតារាង១.៨ ៖ ស្ថានភាពវិនិយោគរបស់វិស័យឯកជន ឆ្នាំ........**

ក្រុមហ៊ុន........................

| វិស័យ | សក្តានុពល (ភាពខ្លាំង) | ឧបសគ្គ (ភាពខ្សោយ) | ការវិនិយោគ (ដំណោះស្រាយ) | តម្រូវការយេនឌ័រ |
|---|---|---|---|---|
| **១. ផ្នែកសេដ្ឋកិច្ច** | | | | |
| | | | | |
| | | | | |
| | | | | |
| **២. ផ្នែកសង្គមកិច្ច** | | | | |
| | | | | |
| | | | | |
| | | | | |
| **៣. ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ** | | | | |
| | | | | |
| | | | | |
| | | | | |
| **៤. ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** | | | | |
| | | | | |
| | | | | |
| | | | | |

កំណត់សម្គាល់ ÷

- របៀបចាត់អាទិភាពនៃដំណោះស្រាយតាមផ្នែក ឬវិស័យ ឬសេវានីមួយៗ អាចប្រើប្រាស់វិធីសាស្ត្រណាមួយតាមស្ថានភាពជាក់ស្តែង ដូចជា ការព្រមព្រៀង ការដាក់ពិន្ទុ ការផ្គូរផ្គងជាដើម។
- ឃុំ សង្កាត់ ការិយាល័យ អង្គភាព អង្គការសង្គមស៊ីវិល និងវិស័យឯកជននានា ត្រូវបញ្ជូនតារាងដែលបានបំពេញមកក្រុមការងារកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ តាមការណែនាំរបស់ក្រុមការងារកសាងផែនការ។

### ១.៣.២. ការរៀបចំគោលការណ៍ណែនាំផ្នែកគោលនយោបាយ

គោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សា គឺជាឯកសារមូលដ្ឋានគន្លឹះសម្រាប់ណែនាំ និងតម្រង់ទិសក្នុងការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ។ ឯកសារណែនាំផ្នែកគោលនយោបាយនេះ ត្រូវផ្អែកលើតម្រូវការមូលដ្ឋាន សក្តានុពលជាក់ស្តែងដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងឯកសារគោលនយោបាយថ្នាក់រាជធានី ខេត្ត និងថ្នាក់ជាតិ។

គោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សាមានដូចជា ៖

- ពង្រឹងការគ្រប់គ្រង និងពង្រីកការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ
- ពង្រឹង និងពង្រីកផលិតកម្មកសិកម្ម
- យកចិត្តទុកដាក់ និងលើកកម្ពស់ទឹកស្អាត និងអនាម័យ
- យកចិត្តទុកដាក់លើការអភិវឌ្ឍន៍ធនធានមនុស្ស

- លើកកម្ពស់ការអភិវឌ្ឍន៍សិប្បកម្ម និងអាជីវកម្ម
- លើកកម្ពស់ការអភិវឌ្ឍន៍តំបន់ទេសចរណ៍បរិស្ថាន
- ពង្រឹងសិទ្ធិអំណាច និងការធ្វើសេចក្តីសម្រេចចិត្តរបស់ស្ត្រី

បន្ទាប់ពីទទួលបានបញ្ហាបញ្ហា និងតម្រូវការរបស់ឃុំ សង្កាត់ ការិយាល័យ អង្គភាព អង្គការសង្គមស៊ីវិល និងស្ថានភាពវិនិយោគរបស់វិស័យឯកជននានា ក្រុមការងាររៀបចំផែនការក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការបូកសរុបបញ្ចូលទៅក្នុងតារាង១.៥ តារាង១.៦ តារាង១.៧ និងតារាង១.៨ ដូចខាងក្រោម ៖

គំរូតារាង១.៥ ៖ តារាងបូកសរុបតម្រូវការជាអាទិភាពរបស់ឃុំ សង្កាត់ក្នុងក្រុង ស្រុក ខណ្ឌ

| វិស័យ និងសកម្មភាព | ដំណោះស្រាយ | អាទិភាព | | | អាទិភាពជាមធ្យម |
|---|---|---|---|---|---|
| | | ឃុំ... | ឃុំ... | ឃុំ... | |
| **១. ផ្នែកសេដ្ឋកិច្ច** | | | | | |
| | | | | | |
| | | | | | |
| **២. ផ្នែកសង្គមកិច្ច** | | | | | |
| | | | | | |
| | | | | | |
| **៣. ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ** | | | | | |
| | | | | | |
| | | | | | |
| **៤. ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** | | | | | |
| | | | | | |
| | | | | | |

គំរូតារាង១.៦ ៖ តារាងបូកសរុបតម្រូវការជាអាទិភាពរបស់ការិយាល័យ អង្គភាពក្នុងក្រុង ស្រុក ខណ្ឌ

| វិស័យ និងសេវា | ដំណោះស្រាយ | ឈ្មោះការិយាល័យ អង្គភាព | | | ចំនួនការិយាល័យដែលបានស្នើ |
|---|---|---|---|---|---|
| | | ការិ. ... | ការិ. ... | ការិ. ... | |
| **១. ផ្នែកសេដ្ឋកិច្ច** | | | | | |
| | | | | | |
| | | | | | |
| **២. ផ្នែកសង្គមកិច្ច** | | | | | |
| | | | | | |
| | | | | | |
| **៣. ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ** | | | | | |
| | | | | | |
| | | | | | |
| **៤. ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** | | | | | |
| | | | | | |
| | | | | | |

គំរូតារាង១.៧ ៖ តារាងបូកសរុបតម្រូវការជាអាទិភាពរបស់អង្គការសង្គមស៊ីវិលក្នុងក្រុង ស្រុក ខណ្ឌ

| វិស័យ និងសេវា | ដំណោះស្រាយ | ឈ្មោះអង្គការ | | | ចំនួនអង្គការដែលបានស្នើ |
|---|---|---|---|---|---|
| | | អង្គការ... | អង្គការ... | អង្គការ... | |
| **១. ផ្នែកសេដ្ឋកិច្ច** | | | | | |
| | | | | | |
| | | | | | |
| **២. ផ្នែកសង្គមកិច្ច** | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| **៣. ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ** | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| **៤. ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** | | | | | |
| | | | | | |
| | | | | | |
| | | | | | |

គំរូតារាង១.៨ ៖ តារាងបូកសរុបការវិនិយោគជាអាទិភាពរបស់វិស័យឯកជនក្នុងក្រុង ស្រុក ខណ្ឌ

| វិស័យ និងសេវា | ដំណោះស្រាយ | ឈ្មោះក្រុមហ៊ុន | | | ចំនួនក្រុមហ៊ុនដែលបានស្នើ |
|---|---|---|---|---|---|
| | | ក្រុមហ៊ុន... | ក្រុមហ៊ុន... | ក្រុមហ៊ុន... | |
| **១. ផ្នែកសេដ្ឋកិច្ច** | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| **២. ផ្នែកសង្គមកិច្ច** | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| **៣. ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ** | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| **៤. ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** | | | | | |
| | | | | | |
| | | | | | |
| | | | | | |

ផ្អែកលើលទ្ធផលនៃការបូកសរុបបញ្ហា និងតម្រូវការរបស់ឃុំ សង្កាត់ ការិយាល័យ អង្គភាព អង្គការសង្គមស៊ីវិល និងស្ថានភាពវិនិយោគរបស់វិស័យឯកជន ក្រុមការងារកសាងផែនការក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំផ្អែកគោលនយោបាយរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដោយផ្អែកជាសំខាន់លើដំណោះស្រាយជាអាទិភាព ដែលបានកំណត់ សក្តានុពលនានារបស់ក្រុង ស្រុក ខណ្ឌ និងគោលនយោបាយរបស់ថ្នាក់រាជធានី ខេត្ត និងថ្នាក់ជាតិ ដូចជា ផែនការអភិវឌ្ឍន៍រាជធានី ខេត្ត យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម

ជាដើម។ ការរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំផ្នែកគោលនយោបាយនេះ ត្រូវមានការចូលរួមពីក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការពាក់ព័ន្ធនានារបស់ក្រុមប្រឹក្សា ដើម្បីធានាភាពជាម្ចាស់របស់ក្រុមប្រឹក្សាលើគោលការណ៍ណែនាំនេះ។ គោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សាត្រូវរៀបចំក្នុងលក្ខណៈជាវិស័យ (ជាចង្កោមសេវាឬសកម្មភាព) និងត្រូវធ្វើការចាត់អាទិភាពជា **ខ្ពស់ មធ្យម** និង**ទាប** ផ្អែកតាមកម្រិតនៃភាពសំខាន់របស់គោលការណ៍ណែនាំទាំងនោះ និងស្ថានភាពជាក់ស្តែងរបស់ក្រុង ស្រុក ខណ្ឌនីមួយៗ។

បន្ទាប់មក ក្រុមការងារកសាងផែនការក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំ និងផ្ញើសេចក្តីព្រាងគោលការណ៍ណែនាំផ្នែកគោលនយោបាយជូនគណៈអភិបាលពិនិត្យ និងផ្តល់យោបល់ មុនពេលដាក់ជូនក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌពិនិត្យ និងអនុម័ត។

គោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សា ត្រូវចេញដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។

### ១.៣.៣. ការរៀបចំប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍

ប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍ គឺផែនការសកម្មភាព ដែលកំណត់អំពីសកម្មភាព ពេលវេលា ទីកន្លែង អ្នកទទួលខុសត្រូវ និងធនធានដែលត្រូវការចាំបាច់ (ដូចទម្រង់គំរូ)។

ក្រុមការងារកសាងផែនការក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំសេចក្តីព្រាងប្រតិទិនការងារនេះ ដើម្បីដាក់ជូនគណៈអភិបាលពិនិត្យ និងផ្តល់យោបល់ មុននឹងដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។

**ទម្រង់គំរូប្រតិទិនការងារកសាងផែនការអភិវឌ្ឍន៍**

| ល.រ | សកម្មភាព | ពេលវេលា | ទីកន្លែង | អ្នកទទួលខុសត្រូវ | ថវិកា | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

ប្រតិទិនការងារកសាងផែនការខាងលើនេះ ត្រូវបានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ......................... អនុម័តក្នុងកិច្ចប្រជុំ............ លើកទី.......... នាថ្ងៃទី.......... ខែ........ ឆ្នាំ............ ។

**ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ**

### ១.៣.៤. ការរៀបចំវឌ្ឍនភាពរបស់ក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា

ការិយាល័យផែនការក្រុង ស្រុក ខណ្ឌ ដោយមានការជួយពីមន្ទីរផែនការរាជធានី ខេត្ត ត្រូវជួយរៀបចំឯកសារស្តីពីវឌ្ឍនភាពរបស់ក្រុង ស្រុក ខណ្ឌ ក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ដោយផ្អែកលើទិន្នន័យមូលដ្ឋានឃុំ សង្កាត់ ដោយធៀបនឹងចំណុចដៅ និងសូចនាករនានានៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ទៅតាមនីតិវិធីដែលបានរៀបចំដោយក្រសួងផែនការ ។

### ១.៣.៥. ការរៀបចំបញ្ជីឯកសារពាក់ព័ន្ធនានា

ក្រុមការងារកសាងផែនការក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យមើលឯកសារទាំងអស់ដែលមានទាក់ទងនឹងការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ និងរៀបចំជាបញ្ជីឯកសារ (ដូចមានទម្រង់គំរូ) ។ ឯកសារទាំងនោះរួមមាន ៖

- គោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សាស្តីពីការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ
- ឯកសារព័ត៌មានស្ថានភាពក្រុង ស្រុក ខណ្ឌ ដែលបានមកពីការធ្វើទិន្នន័យមូលដ្ឋានឃុំ សង្កាត់
- សេចក្តីសង្ខេបព័ត៌មានស្ថានភាពក្រុង ស្រុក ខណ្ឌ តាមផ្នែកនីមួយៗ (ទម្រង់គំរូ)
- ឯកសារវឌ្ឍនភាពនៃការកាត់បន្ថយភាពក្រីក្រ ក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់ថ្នាក់មូលដ្ឋាន (ផ្តល់ដោយការិយាល័យផែនការក្រុង ស្រុក ខណ្ឌ)
- ឯកសារពតិមានពីដៃគូអភិវឌ្ឍន៍នានាដែលមានសកម្មភាពក្នុងក្រុង ស្រុក ខណ្ឌ
- បណ្តាផែនទីធំៗ (ទំហំ A0 ឬ A1) (ប្រើប្រាស់ក្នុងកិច្ចប្រជុំកសាងផែនការ ) ដូចជា ៖
  - ផែនទីភូមិសាស្ត្ររដ្ឋបាលបង្ហាញពីព្រំប្រទល់ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ ដែលចេញដោយក្រសួងមហាផ្ទៃ
  - ផែនទីបង្ហាញពីដង់ស៊ីតេប្រជាជនតាមភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ
  - ផែនទីបង្ហាញដោយសាមញ្ញពីការប្រើប្រាស់ដីធ្លី (ទីប្រជុំជន កសិកម្ម ព្រៃឈើ ។ល។)
  - ផែនទីបង្ហាញហេដ្ឋារចនាសម្ព័ន្ធសង្គមសំខាន់ៗ (អនុវិទ្យាល័យ មណ្ឌលសុខភាព ការិយាល័យរដ្ឋបាលសាធារណៈ និងទីផ្សារជាដើម) ។ល។
- ឯកសារផែនការអភិវឌ្ឍន៍ពីមុនរបស់ក្រុង ស្រុក ខណ្ឌ (បើមាន)
- ផែនការអភិវឌ្ឍន៍របស់វិស័យ និង ឬថ្នាក់គ្រប់គ្រងរដ្ឋបាលពាក់ព័ន្ធនានា
- តារាងម៉ាទ្រិចសកម្មភាពអាទិភាពរបស់ក្រុង ស្រុក ខណ្ឌ (យកតាមកាលបរិច្ឆេទចុងក្រោយគេ)
- តារាងបញ្ហា និងតម្រូវការសំខាន់ៗមួយចំនួន ដូចខាងក្រោម ៖
  - តារាង១.១ ៖ បញ្ហា និងតម្រូវការជាអាទិភាពរបស់ឃុំ សង្កាត់នីមួយៗ
  - តារាង១.២ ៖ បញ្ហា និងតម្រូវការជាអាទិភាពរបស់ការិយាល័យ អង្គភាពក្នុងក្រុង ស្រុក ខណ្ឌ
  - តារាង១.៣ ៖ បញ្ហា និងតម្រូវការជាអាទិភាពរបស់អង្គការសង្គមស៊ីវិលក្នុងក្រុង ស្រុក ខណ្ឌ
  - តារាង១.៤ ៖ ស្ថានភាពវិនិយោគរបស់វិស័យឯកជន
  - តារាង១.៥ ៖ តារាងបូកសរុបតម្រូវការជាអាទិភាពរបស់សង្កាត់ក្នុងក្រុង ស្រុក ខណ្ឌ

- តារាង១.៦ ៖ តារាងបូកសរុបតម្រូវការជាអាទិភាពរបស់ការិយាល័យអង្គភាពក្នុងក្រុង ស្រុក ខណ្ឌ
- តារាង១.៧ ៖ តារាងបូកសរុបតម្រូវការជាអាទិភាពរបស់អង្គការសង្គមស៊ីវិលក្នុងក្រុង ស្រុក ខណ្ឌ
- តារាង១.៨ ៖ តារាងបូកសរុបការវិនិយោគជាអាទិភាពរបស់វិស័យឯកជន

**ទម្រង់គំរូបញ្ជីតម្រូវការឯកសារ**

| ល.រ | ឈ្មោះឯកសារ | ប្រភេទ | កាលបរិច្ឆេទ | ប្រភព | ទីកន្លែងកម្កល់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

**ទម្រង់គំរូសេចក្តីសង្ខេបព័ត៌មានស្ថានភាពក្រុង ស្រុក ខណ្ឌ**

| បរិយាយ | ឯកតា | ២០០៧ | ២០០៨ | ២០០៩ | ២០១០ |
|---|---|---|---|---|---|
| **ទិន្នន័យទូទៅ** | | | | | |
| ផ្ទៃដីក្រុង ស្រុក ខណ្ឌ | | | | | |
| ចំនួនឃុំ សង្កាត់ | | | | | |
| ចំនួនភូមិ | | | | | |
| ចំនួនប្រជាពលរដ្ឋ | | | | | |
| ចំនួនគ្រួសារ | | | | | |
| ទំហំគ្រួសារជាមធ្យម | | | | | |
| ដង់ស៊ីតេប្រជាពលរដ្ឋ | | | | | |
| កំណើនប្រជាពលរដ្ឋ | | | | | |
| ភាគរយគ្រួសារក្រីក្រ | | | | | |
| ....... | | | | | |
| **ទិន្នន័យផ្នែកសេដ្ឋកិច្ច** | | | | | |
| ភាគរយគ្រួសារមានមុខរបរកសិកម្មជាចម្បង ៖ | | | | | |
| ធ្វើស្រែ | | | | | |
| ធ្វើចំការ | | | | | |

| បរិយាយ | ឯកតា | ២០០៧ | ២០០៨ | ២០០៩ | ២០១០ |
|---|---|---|---|---|---|
| នេសាទ | | | | | |
| ការចិញ្ចឹមសត្វ | | | | | |
| ....... | | | | | |
| ភាគរយគ្រួសារមានមុខរបរធ្វើសិប្បកម្មជាចម្បង ៖ | | | | | |
| សិប្បកម្មផលិតគ្រឿងសង្ហារិម | | | | | |
| សិប្បកម្មតម្បាញរវៃ ក្រមា ហូល.... | | | | | |
| ..... | | | | | |
| ភាគរយគ្រួសារមានមុខរបរសេវាកម្មជាចម្បង ៖ | | | | | |
| មុខរបរជំនួញ | | | | | |
| មុខរបរជាង | | | | | |
| សេវាទេសចរណ៍ | | | | | |
| ............ | | | | | |
| **ទិន្នន័យផ្នែកសង្គមកិច្ច** | | | | | |
| ភាគរយកុមារអាយុ ៣-៥ ឆ្នាំចូលរៀនក្នុងមត្តេយ្យសាលា | | | | | |
| ភាគរយកុមារអាយុ ៦-១១ ឆ្នាំចូលរៀនក្នុងបឋមសិក្សា | | | | | |
| ភាគរយយុវជនអាយុ១៥-១៧ ឆ្នាំមិនបាននៅរៀន | | | | | |
| ភាគរយអ្នកមិនចេះអក្សរសរុបអាយុពី១៥-៦០ឆ្នាំ | | | | | |
| ភាគរយស្ត្រីសម្រាលកូនដោយឆ្មបបុរាណ | | | | | |
| អត្រាមរណភាពមាតាក្រោយពេលសម្រាលកូន (០-១ខែ) ក្នុង ១០០.០០០ កំណើត | | | | | |
| អត្រាមរណភាពទារកអាយុ០-១ខែក្នុង១០០០ កំណើតរស់ | | | | | |
| ភាគរយកុមារអាយុ ៩-១២ឆ្នាំមិនបានចាក់ថ្នាំបង្ការគ្រប់ចំនួន | | | | | |
| ភាគរយគ្រួសារប្រើប្រាស់ទឹកពីប្រភពទឹកស្អាតនៅរដូវប្រាំង | | | | | |
| ភាគរយគ្រួសារប្រើប្រាស់ទឹកពីប្រភពទឹកមិនស្អាតនៅរដូវប្រាំង | | | | | |
| ..................... | | | | | |
| ភាគរយគ្រួសារមានបង្គន់អនាម័យ | | | | | |
| **ទិន្នន័យផ្នែកដីធ្លី ធនធានធម្មជាតិ និងបរិស្ថាន** | | | | | |
| ចំនួនគ្រួសាររងគ្រោះដោយគ្រោះធម្មជាតិ | | | | | |
| ចំនួនជនរងគ្រោះដោយសារគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ | | | | | |
| ចំនួនគ្រួសារមានសេវាប្រមូលសំរាម | | | | | |

| បរិយាយ | ឯកតា | ២០០៧ | ២០០៨ | ២០០៩ | ២០១០ |
|---|---|---|---|---|---|
| ចំនួនគ្រួសារទទួលរងនូវការបំពុលបរិស្ថាន | | | | | |
| គ្រួសារដាំដុះដោយប្រើជីគីមី | | | | | |
| គ្រោះទឹកជំនន់ដែលកើតមានឡើង | | | | | |
| គ្រោះរាំងស្ងួតដែលកើតមានឡើអ | | | | | |
| គ្រោះអគ្គិភ័យដែលកើតមានឡើង | | | | | |
| ............................. | | | | | |
| **ទិន្នន័យផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់** | | | | | |
| ភាគរយទារកមិនបានចុះសំបុត្រកំណើតក្នុងឆ្នាំ | | | | | |
| ចំនួនគ្រួសារមានផ្ទះនៅលើដីសាធារណៈ | | | | | |
| ចំនួនជនអានាថាគ្មានទីពឹង | | | | | |
| ចំនួនជនរងគ្រោះដោយសារការរំលោភផ្លូវភេទ | | | | | |
| ចំនួនជនរងគ្រោះដោយសារការជួញដូរមនុស្ស | | | | | |
| ចំនួនករណីលួច | | | | | |
| ចំនួនករណីទំនាស់ដីធ្លី | | | | | |
| ចំនួនគ្រួសារមានអំពើហិង្សាក្នុងគ្រួសារ | | | | | |
| ចំនួនករណីគ្រោះថ្នាក់ដោយចរាចរណ៍ | | | | | |
| ......................... | | | | | |

**កំណត់សម្គាល់** ÷ ចំពោះក្រុង ស្រុក ខណ្ឌ ដែលមានជនជាតិដើមភាគតិចរស់នៅច្រើន ត្រូវបញ្ចូលតារាងបង្ហាញពីភាគរយនៃប្រជាជន ដែលជាជនជាតិដើមភាគតិចតាមប្រភេទនីមួយៗ។

## ជំហានទី២ ÷ ការផ្សព្វផ្សាយព័ត៌មានអំពីការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ

### ២.១. គោលបំណង

គោលបំណងសំខាន់នៃជំហាននេះ គឺការផ្សព្វផ្សាយព័ត៌មានស្តីពីគោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ តម្រូវការ និងដំណើរការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ និងប្រតិទិនការងារសម្រាប់កសាងផែនការ ព្រមទាំងឯកសារពាក់ព័ន្ធនានា ដែលជាមូលដ្ឋានសម្រាប់ប្រើប្រាស់ក្នុងពេលកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ។

### ២.២. លទ្ធផលរំពឹងទុក

លទ្ធផលរំពឹងទុកក្នុងជំហាននេះ គឺ ៖

- អ្នកពាក់ព័ន្ធនានាយល់ដឹងអំពីគោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សាសម្រាប់កិច្ចអភិវឌ្ឍក្នុងដែនសមត្ថកិច្ចរបស់ក្រុង ស្រុក ខណ្ឌ
- បញ្ជីបូកសរុបបញ្ហា និងតម្រូវការពីគ្រប់ឃុំ សង្កាត់ក្នុងក្រុង ស្រុក ខណ្ឌ
- បញ្ជីបូកសរុបបញ្ហា និងតម្រូវការរបស់ការិយាល័យ អង្គភាព និងអង្គការសង្គមស៊ីវិលក្នុងក្រុង ស្រុក ខណ្ឌ
- បញ្ជីបូកសរុបការវិនិយោគជាអាទិភាពរបស់វិស័យឯកជន
- អ្នកពាក់ព័ន្ធនានាយល់ដឹងពីដំណើរ និងនីតិវិធីក្នុងការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ
- អ្នកពាក់ព័ន្ធនានាយល់ដឹងអំពីតម្រូវការឯកសារនានា ដែលត្រូវយកមកប្រើក្នុងការកសាងផែនការអភិវឌ្ឍន៍
- ប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍។

### ២.៣. ដំណើរការ

#### ក). សមាសភាពចូលរួម

កិច្ចប្រជុំផ្សព្វផ្សាយព័ត៌មានស្តីពីការកសាងផែនការអភិវឌ្ឍន៍ ត្រូវស្ថិតក្រោមការដឹកនាំរបស់អភិបាលក្រុង ស្រុក ខណ្ឌ និងមានការចូលរួមពីសមាជិកសំខាន់ៗរួមមាន ៖

- តំណាងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ
- គណៈអភិបាលក្រុង ស្រុក ខណ្ឌ
- ក្រុមការងារកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ
- តំណាងក្រុមប្រឹក្សាគ្រប់ឃុំ សង្កាត់
- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស និងគណៈកម្មាធិការផ្សេងទៀតរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ
- តំណាងសមាគមក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- តំណាងអង្គការសង្គមស៊ីវិលដែលមានក្នុងក្រុង ស្រុក ខណ្ឌ
- តំណាងវិស័យឯកជននិង
- អ្នកពាក់ព័ន្ធដទៃទៀតតាមការចាំបាច់។

**៦).	របៀបវារៈ**

របៀបវារៈសំខាន់ៗក្នុងអង្គប្រជុំផ្សព្វផ្សាយរួមមាន ៖

១. បទបង្ហាញអំពីប្រកាសអន្តរក្រសួងស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

២. បទបង្ហាញអំពីគោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ

៣. បទបង្ហាញអំពីដំណើរការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ

៤. បទបង្ហាញអំពី ៖

- តារាង១.៥ ៖ តារាងបូកសរុបតម្រូវការជាអាទិភាពរបស់ឃុំ សង្កាត់ក្នុងក្រុង ស្រុក ខណ្ឌ
- តារាង១.៦ ៖ តារាងបូកសរុបតម្រូវការជាអាទិភាពរបស់ការិយាល័យ អង្គភាពក្នុងក្រុង ស្រុក ខណ្ឌ
- តារាង១.៧ ៖ តារាងបូកសរុបតម្រូវការជាអាទិភាពរបស់អង្គការសង្គមស៊ីវិលក្នុងក្រុង ស្រុក ខណ្ឌ
- តារាង១.៨ ៖ តារាងបូកសរុបការវិនិយោគជាអាទិភាពរបស់វិស័យឯកជន
- ទិន្នន័យព័ត៌មានស្ថានភាពក្រុង ស្រុក ខណ្ឌ
- វឌ្ឍនភាពរបស់ក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា

៥. សំណួរ និងចម្លើយ

៦. បទបង្ហាញអំពីប្រតិទិនការងារសម្រាប់ដំណើរកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ

៧. ផ្សេងៗ។

# ជំហានទី៣ ៖ ការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ

## ៣.១. គោលបំណង

គោលបំណងសំខាន់នៃជំហាននេះ គឺរៀបចំនិងចងក្រងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ សម្រាប់ដាក់ជូនគណៈអភិបាលពិនិត្យ និងផ្តល់យោបល់ មុននឹងដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។

## ៣.២. លទ្ធផលរំពឹងទុក

លទ្ធផលសំខាន់ដែលរំពឹងថានឹងសម្រេចបានក្នុងជំហាននេះ គឺសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ រយៈពេលប្រាំឆ្នាំ ដែលឆ្លុះបញ្ចាំងអំពីស្ថានភាពអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ក្របខ័ណ្ឌអភិវឌ្ឍន៍ និងការចាត់ចែងតាមដានការអនុវត្តផែនការអភិវឌ្ឍន៍។

## ៣.៣. ដំណើរការ

ដំណើរការនៃការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ចែកជាដំណាក់កាល ៖

- ការវិភាគស្ថានភាព
- ការរៀបចំក្របខ័ណ្ឌអភិវឌ្ឍន៍
- ការរៀបចំយុទ្ធសាស្ត្រតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍
- ការសរសេរសេចក្តីព្រាងផែនការអភិវឌ្ឍន៍
- កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងបឋមស្តីពីផែនការអភិវឌ្ឍន៍
- ការពិនិត្យ និងផ្តល់យោបល់របស់គណៈអភិបាលលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍
- ការពិនិត្យ និងផ្តល់យោបល់របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍

### ៣.៣.១. ការវិភាគស្ថានភាពក្រុង ស្រុក ខណ្ឌ

**ក). គោលបំណង**

គោលបំណងនៃការវិភាគស្ថានភាពក្រុង ស្រុក ខណ្ឌ គឺដើម្បីធ្វើការពិភាក្សា និងរកទស្សនៈឯកភាពអំពីបណ្តាបញ្ហាកំពុងកើតមាន អាចនឹងកើតមាន មូលហេតុ និងដំណោះស្រាយនានាក្នុងអាណត្តិរបស់ក្រុមប្រឹក្សា។

**ខ). លទ្ធផលរំពឹងទុក**

លទ្ធផលសំខាន់ៗដែលរំពឹងថានឹងសម្រេចបាន គឺបញ្ហា មូលហេតុ និងដំណោះស្រាយត្រូវបានកំណត់តាមផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ច ផ្នែគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ និងផ្នែករដ្ឋបាលនិងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ។

**ត). សមាសភាពអ្នកចូលរួម និងការទទួលខុសត្រូវ**

អ្នកចូលរួមក្នុងការវិភាគស្ថានភាពនេះ រួមមានមន្ត្រីបច្ចេកទេសពីការិយាល័យ អង្គភាពនានាដែលពាក់ព័ន្ធនឹងផ្នែកនីមួយៗ មន្ត្រីពាក់ព័ន្ធនានានៃការិយាល័យសាលាក្រុង ស្រុក ខណ្ឌ សមាជិកនៃគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដូចជា តំណាងក្រុមប្រឹក្សា និងរដ្ឋបាលប្រភេទរួមគ្នា និងប្រភេទផ្សេងគ្នា តំណាងអង្គការសង្គមស៊ីវិល និងផ្នែកឯកជនជាដើម។

ក្រុមការងារកសាងផែនការ ការិយាល័យផែនការក្រុង ស្រុក ខណ្ឌ និងការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ត្រូវដឹកនាំ និងសម្របសម្រួលការពិភាក្សាតាមផ្នែកនីមួយៗ។

**ថ). ឯកសារសំខាន់ៗបម្រើឱ្យការប្រជុំវិភាគ**

ឯកសារ ឬព័តិមានសម្រាប់ធ្វើជាឧបករណ៍ក្នុងពេលប្រជុំវិភាគស្ថានភាពក្រុង ស្រុក ខណ្ឌ រួមមាន៖

១. សេចក្តីសង្ខេបកម្រងព័តិមានស្ថានភាពក្រុង ស្រុក ខណ្ឌ

២. តារាង១.២ ដែលបំពេញដោយការិយាល័យ អង្គភាពនីមួយៗ

៣. តារាង១.៣ ដែលបំពេញដោយអង្គការសង្គមស៊ីវិលនីមួយៗ

៤. តារាង១.៤ ដែលបំពេញដោយវិស័យឯកជននីមួយៗ

៥. តារាង១.៥ ៖ តារាងបូកសរុបតម្រូវការជាអាទិភាពរបស់ឃុំ សង្កាត់ក្នុងក្រុង ស្រុក ខណ្ឌ

៦. តារាង១.៦ ៖ តារាងបូកសរុបតម្រូវការជាអាទិភាពរបស់ការិយាល័យ អង្គភាពក្នុងក្រុង ស្រុក ខណ្ឌ

៧. តារាង១.៧ ៖ តារាងបូកសរុបតម្រូវការជាអាទិភាពរបស់អង្គការសង្គមស៊ីវិលក្នុងក្រុង ស្រុក ខណ្ឌ

៨. តារាង១.៨ ៖ តារាងបូកសរុបការវិនិយោគជាអាទិភាពរបស់វិស័យឯកជន

៩. បណ្តាផែនទីភូមិសាស្ត្ររដ្ឋបាល សេដ្ឋកិច្ច ធនធានធម្មជាតិក្នុងក្រុង ស្រុក ខណ្ឌ ។ល។

១០. ឯកសារគោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ

១១. វឌ្ឍនភាពរបស់ក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា

១២. ឯកសារពាក់ព័ន្ធនានា។

**ង). ការប្រជុំណែនាំស្តីពីដំណើរការវិភាគស្ថានភាព**

ដើម្បីឱ្យដំណើរការវិភាគនេះ អនុវត្តទៅប្រកបដោយប្រសិទ្ធភាព ក្រុមការងារកសាងផែនការត្រូវរៀបចំកិច្ចប្រជុំរួមមួយ ដើម្បីធ្វើការបង្ហាញ និងណែនាំដល់អ្នកចូលរួមទាំងអស់អំពីទិន្នន័យ និងឧបករណ៍ចាំបាច់នានាសម្រាប់ការវិភាគនេះ។

អ្នកចូលរួមក្នុងការប្រជុំវិភាគ គួរត្រូវបែងចែកជាបួនក្រុមសម្រាប់វិភាគលើ៖

- ក្រុមទី១ ៖ ផ្នែកសេដ្ឋកិច្ច
- ក្រុមទី២ ៖ ផ្នែកសង្គមកិច្ច
- ក្រុមទី៣ ៖ ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ
- ក្រុមទី៤ ៖ ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

**បញ្ជាក់** ៖ ក្រុមនីមួយៗអាចបែងចែកជាក្រុមតូចៗទៀតតាមការចាំបាច់របស់ក្រុម។

**ក្រុមទី១ ÷ ផ្នែកសេដ្ឋកិច្ច**

សមាសភាពដែលត្រូវចូលរួមក្នុងការវិភាគផ្នែកសេដ្ឋកិច្ច រួមមានតំណាងមកពី ៖

- គណៈកម្មាធិការពាក់ព័ន្ធនានារបស់ក្រុមប្រឹក្សា
- ការិយាល័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ការិយាល័យធនធានទឹក និងឧតុនិយម
- ការិយាល័យទេសចរណ៍
- ការិយាល័យឧស្សាហកម្ម រ៉ែ និងថាមពល
- ការិយាល័យសាធារណការ និងដឹកជញ្ជូន
- ការិយាល័យអភិវឌ្ឍន៍ជនបទ
- ការិយាល័យប្រៃសណីយ៍ និងទូរគមនាគមន៍
- ការិយាល័យផែនការ
- ការិយាល័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់
- ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ
- ការិយាល័យអន្តរវិស័យ
- អង្គការសង្គមស៊ីវិលពាក់ព័ន្ធ តាមការចាំបាច់
- វិស័យឯកជនពាក់ព័ន្ធ តាមការចាំបាច់
- .....

**ក្រុមទី២ ÷ ផ្នែកសង្គមកិច្ច**

សមាសភាពដែលត្រូវចូលរួមក្នុងការវិភាគផ្នែកសង្គមកិច្ច រួមមានតំណាងមកពី ៖

- គណៈកម្មាធិការពាក់ព័ន្ធនានារបស់ក្រុមប្រឹក្សា
- ការិយាល័យអប់រំ យុវជន និងកីឡា
- ការិយាល័យសុខាភិបាល
- ការិយាល័យកិច្ចការនារី
- ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ការិយាល័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ការិយាល័យធម្មការ និងសាសនា
- ការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈ
- ការិយាល័យពាក់ព័ន្ធនានារបស់សាលាក្រុង ស្រុក ខណ្ឌ
- អង្គការសង្គមស៊ីវិលពាក់ព័ន្ធ តាមការចាំបាច់
- វិស័យឯកជនពាក់ព័ន្ធ តាមការចាំបាច់
- .....

**ក្រុមទី៣ ÷ ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ**

សមាសភាពដែលត្រូវចូលរួមក្នុងការវិភាគផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ រួមមានតំណាងមកពី ៖

- គណៈកម្មាធិការពាក់ព័ន្ធនានារបស់ក្រុមប្រឹក្សា
- ការិយាល័យបរិស្ថាន
- ការិយាល័យទេសចរណ៍
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ខណ្ឌរដ្ឋបាលព្រៃឈើ
- ខណ្ឌរដ្ឋបាលជលផល
- គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្រុង ស្រុក ខណ្ឌ
- ការិយាល័យពាក់ព័ន្ធនានារបស់សាលាក្រុង ស្រុក ខណ្ឌ
- អង្គការសង្គមស៊ីវិលពាក់ព័ន្ធ តាមការចាំបាច់
- វិស័យឯកជនពាក់ព័ន្ធ តាមការចាំបាច់
- .....

**ក្រុមទី៤ ÷ ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**

សមាសភាពដែលត្រូវចូលរួមក្នុងការវិភាគផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈរួមមានតំណាងមកពី ៖

- គណៈកម្មាធិការពាក់ព័ន្ធនានារបស់ក្រុមប្រឹក្សា
- ការិយាល័យពាក់ព័ន្ធនានារបស់សាលាក្រុង ស្រុក ខណ្ឌ
- អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- កងរាជអាវុធហត្ថក្រុង ស្រុក ខណ្ឌ
- ការិយាល័យកិច្ចការនារី
- កាកបាទក្រហមក្រុង ស្រុក ខណ្ឌ
- ការិយាល័យសាធារណការ និងដឹកជញ្ជូន
- ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- អង្គការសង្គមស៊ីវិលពាក់ព័ន្ធនានា តាមការចាំបាច់
- វិស័យឯកជនពាក់ព័ន្ធនានា
- .....

ក្នុងការបែងចែកសមាសភាពក្រុមវិភាគតាមផ្នែកនីមួយៗខាងលើ អាចធ្វើការផ្លាស់ប្តូរតាមតម្រូវការចាំបាច់របស់ក្រុង ស្រុក ខណ្ឌនីមួយៗ។

កិច្ចប្រជុំវិភាគស្ថានភាពនេះ ត្រូវស្ថិតនៅក្រោមអធិបតីភាពរបស់អភិបាលក្រុង ស្រុក ខណ្ឌ ដែលជាប្រធានក្រុមការងារកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ តាមរបៀបវារៈដូចខាងក្រោម ៖

១. ការបង្ហាញគោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ

២. ការបង្ហាញអំពីសេចក្តីសង្ខេបកម្រងព័ត៌មានស្ថានភាពក្រុង ស្រុក ខណ្ឌ តាមផ្នែកនីមួយៗ

៣. ការបង្ហាញអំពី ៖

- តារាង១.៥ ៖ តារាងបូកសរុបតម្រូវការជាអាទិភាពរបស់ឃុំ សង្កាត់ក្នុងក្រុង ស្រុក ខណ្ឌ
- តារាង១.៦ ៖ តារាងបូកសរុបតម្រូវការជាអាទិភាពរបស់ការិយាល័យ អង្គភាពក្នុងក្រុង ស្រុក ខណ្ឌ
- តារាង១.៧ ៖ តារាងបូកសរុបតម្រូវការជាអាទិភាពរបស់អង្គការសង្គមស៊ីវិលក្នុងក្រុង ស្រុក ខណ្ឌ
- តារាង១.៨ ៖ តារាងបូកសរុបការវិនិយោគជាអាទិភាពរបស់វិស័យឯកជនក្នុងក្រុង ស្រុក ខណ្ឌ

៤. ការបង្ហាញអំពីបណ្តាផែនទីភូមិសាស្ត្ររដ្ឋបាល សេដ្ឋកិច្ច ធនធានធម្មជាតិក្នុងក្រុង ស្រុក ខណ្ឌ ។ល។

៥. វឌ្ឍនភាពរបស់ក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា

៦. ការបង្ហាញអំពីវិធីសាស្ត្រ និងឧបករណ៍សម្រាប់វិភាគ

៧. សំណួរ ចម្លើយ

៨. ការណែនាំ និងការបែងចែកក្រុមពិភាក្សា (បែងចែកតាមការកំណត់ខាងលើ)

៩. ផ្សេងៗ ។

## ច). ដំណើរការវិភាគ

បន្ទាប់ពីកិច្ចប្រជុំណែនាំស្តីពីដំណើរការនៃការវិភាគស្ថានភាពក្រុង ស្រុក ខណ្ឌរួចមក ក្រុមពិភាក្សាតាមផ្នែកនីមួយៗ ត្រូវចាប់ផ្តើមធ្វើការពិភាក្សាក្នុងរយៈពេលមួយសមស្រប ដើម្បីកំណត់ឱ្យបានច្បាស់លាស់ពីបញ្ហា មូលហេតុ និងដំណោះស្រាយ ។ ក្នុងដំណើរការវិភាគស្ថានភាពនេះ ក្រុមពិភាក្សាតាមផ្នែកនីមួយៗ ត្រូវប្រើប្រាស់ឧបករណ៍វិភាគនានា ដូចជាឧបករណ៍វិភាគយេនឌ័រ ឧបករណ៍វិភាគធនធានធម្មជាតិ ឧបករណ៍វិភាគគ្រោះមហន្តរាយ ជាដើម ។

ការវិភាគស្ថានភាពត្រូវអនុវត្តតាមដំណើរការដូចខាងក្រោម ៖

### ច.១. ការវិភាគផ្នែកសេដ្ឋកិច្ច

ដំបូង ត្រូវធ្វើការកំណត់ និងពិភាក្សាវិស័យចម្បងៗក្នុងផ្នែកសេដ្ឋកិច្ចរបស់ក្រុង ស្រុក ខណ្ឌ ។ ការកំណត់នេះត្រូវផ្អែកលើទិន្នន័យ និងតារាងបញ្ហា តម្រូវការ ដូចជាតារាង១.៥ តារាង១.៦ តារាង១.៧ និងតារាង១.៨ និងស្ថានភាពជាក់ស្តែងរបស់ក្រុង ស្រុក ខណ្ឌនីមួយៗ ។ ក្នុងការវិភាគវិស័យចម្បងនេះ ក្រុមពិភាក្សា ត្រូវពិនិត្យ ពិភាក្សា និងកំណត់នូវមុខរបរ សកម្មភាព ឬសេវាសំខាន់ៗនៃវិស័យចម្បងនីមួយៗ ដែលជាមូលដ្ឋានគាំទ្រដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋនៅក្នុងក្រុង ស្រុក ខណ្ឌ ។

បន្ទាប់មកត្រូវធ្វើការវិភាគអំពីសក្តានុពល(ភាពខ្លាំង) បញ្ហាប្រឈម(ភាពខ្សោយ) មូលហេតុ និងដំណោះស្រាយតាមវិស័យនីមួយៗ ព្រមទាំងតម្រូវការយេនឌ័រតាមដំណោះស្រាយនីមួយៗនោះ ។ លទ្ធផលនៃការវិភាគនេះ ត្រូវស្រង់ចូលក្នុងតារាង២.១ ស្តីពីការវិភាគផ្នែកសេដ្ឋកិច្ចដូចខាងក្រោម ។

**គំរូតារាង២.១ ៖ ការវិភាគផ្នែកសេដ្ឋកិច្ច**

| វិស័យ និង សកម្មភាពចម្បងៗ | សក្តានុពល (ភាពខ្លាំង) | បញ្ហា (ភាពខ្សោយ) | ទំហំបញ្ហា | មូលហេតុ | ដំណោះស្រាយ | តម្រូវការ យេនឌ័រ |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

### ច.២. ការវិភាគផ្នែកសង្គមកិច្ច

ការវិភាគផ្នែកសង្គមកិច្ច ត្រូវពិភាក្សាលើចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

ទី១ ៖ វិភាគអំពីការងារសង្គមកិច្ច

ទី២ ៖ វិភាគអំពីភាពក្រីក្រ

ទី៣ ៖ វិភាគអំពីការងារយេនឌ័រ

### *ច.២.១. ការវិភាគអំពីការងារសង្គមកិច្ច*

ដំបូងត្រូវធ្វើការកំណត់ និងពិភាក្សាវិស័យចម្បងៗដូចជា វិស័យអប់រំ សុខាភិបាល ទឹកស្អាត និងអនាម័យជាដើម។ ការកំណត់នេះត្រូវផ្អែកលើទិន្នន័យ និងតារាងបញ្ហា តម្រូវការ ដូចជាតារាង១.៥ តារាង១.៦ តារាង១.៧ និងតារាង១.៨ និងស្ថានភាពជាក់ស្តែងរបស់ក្រុង ស្រុក ខណ្ឌនីមួយៗ។ ក្នុងការវិភាគលើវិស័យចម្បងខាងលើនេះ ក្រុមពិភាក្សាត្រូវពិនិត្យ ពិភាក្សា និងកំណត់នូវសកម្មភាព ឬសេវាសំខាន់ៗ ដែលជាមូលដ្ឋានគាំទ្រដល់ការរស់នៅរបស់ ប្រជាពលរដ្ឋក្នុងក្រុង ស្រុក ខណ្ឌ ប្រកបដោយសុខុមាលភាព។

បន្ទាប់មកត្រូវធ្វើការវិភាគអំពីសក្តានុពល(ភាពខ្លាំង) បញ្ហាប្រឈម(ភាពខ្សោយ) ទំហំនៃបញ្ហា មូលហេតុ និង ដំណោះស្រាយតាមវិស័យនីមួយៗ ព្រមទាំងតម្រូវការយេនឌ័រតាមដំណោះស្រាយនីមួយៗនោះ។ លទ្ធផលនៃការវិភាគ នេះ ត្រូវស្រង់ចូលក្នុងតារាង២.២ ស្តីពីការវិភាគការងារសង្គមកិច្ចដូចខាងក្រោម។

**គំរូតារាង២.២ ៖ ការវិភាគការងារសង្គមកិច្ច**

| វិស័យ និងសកម្មភាព ឬសេវាចម្បងៗ | សក្តានុពល (ភាពខ្លាំង) | បញ្ហា (ភាពខ្សោយ) | ទំហំបញ្ហា | មូលហេតុ | ដំណោះស្រាយ | តម្រូវការ យេនឌ័រ |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

### ៥.២.២. ការវិភាគអំពីភាពក្រីក្រ

ការវិភាគអំពីភាពក្រីក្រ ត្រូវពិចារណាពីកត្តាសំខាន់ៗដែលនាំឱ្យគ្រួសារមួយចំនួនធ្លាក់ខ្លួនក្រ កត្តាដែលនាំឱ្យគ្រួសារក្រីក្រមួយចំនួនមានការលំបាកក្នុងការកែលម្អជីវភាពរបស់ខ្លួន និងកត្តានាំឱ្យគ្រួសារក្រីក្រមួយចំនួនបានកែលម្អជីវភាពរបស់ខ្លួន។

ការកំណត់នេះ ត្រូវផ្អែកលើទិន្នន័យ និងស្ថានភាពជាក់ស្តែងរបស់ក្រុង ស្រុក ខណ្ឌនីមួយៗ។ បន្ទាប់មក ត្រូវវិភាគពីមូលហេតុ និងដំណោះស្រាយ ព្រមទាំងតម្រូវការយេនឌ័រតាមដំណោះស្រាយនីមួយៗនោះ។ លទ្ធផលនៃការវិភាគនេះត្រូវស្រង់ចូលក្នុងតារាង២.៣ ស្តីពីការវិភាគភាពក្រីក្រ ដូចខាងក្រោម។

**គំរូតារាង២.៣ ៖ ការវិភាគភាពក្រីក្រ**

| អត្រាភាពក្រីក្រក្នុងអំឡុង៣ឆ្នាំចុងក្រោយ | | | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ |
|---|---|---|---|---|---|
| ២០០៨ | ២០០៩ | ២០១០ | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

### ៥.២.៣. ការវិភាគអំពីការងារយេនឌ័រ

ការងារយេនឌ័រជាការងារអន្តរវិស័យ ដែលមានទាក់ទងនៅគ្រប់ផ្នែក និងគ្រប់វិស័យ។ ការវិភាគខាងលើបានផ្តោតការយកចិត្តទុកដាក់ជាទូទៅលើបញ្ហាយេនឌ័រនេះរួចហើយ។ ហេតុនេះក្រុមវិភាគអំពីការងារយេនឌ័រនេះគួរពិចារណាតែលើបញ្ហាសំខាន់ៗដែលស្ត្រី និងកុមារកំពុងជួបប្រទះ កម្រិតផលប៉ះពាល់នៃបញ្ហាទាំងនោះ មូលហេតុ និងកំណត់រកដំណោះស្រាយសមស្របនានា ដើម្បីជួយឱ្យស្ត្រី និងកុមារដោះស្រាយការលំបាកទាំងនោះបាន។ គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមាររបស់ក្រុមប្រឹក្សា មានតួនាទី និងភារកិច្ចយ៉ាងសំខាន់ក្នុងការវិភាគនេះ។

លទ្ធផលនៃការវិភាគត្រូវស្រង់បញ្ចូលក្នុងតារាង២.៤ ស្តីពីការវិភាគអំពីការងារយេនឌ័រដូចខាងក្រោម។

**គំរូតារាង២.៤ ៖ ការវិភាគអំពីការងារយេនឌ័រ**

| បញ្ហាសំខាន់ៗ | កម្រិតប៉ះពាល់ | មូលហេតុ | ដំណោះស្រាយ |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |

### ច.៣. ការវិភាគផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ

ការវិភាគផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ ត្រូវពិភាក្សាលើចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

ទី១ ៖ ការវិភាគអំពីការប្រើប្រាស់ដីធ្លី

ទី២ ៖ ការវិភាគអំពីធនធានធម្មជាតិ

ទី៣ ៖ ការវិភាគអំពីបរិស្ថាន

ទី៤ ៖ ការវិភាគអំពីគ្រោះមហន្តរាយ

ទី៥ ៖ ការវិភាគអំពីបញ្ហាប្រែប្រួលអាកាសធាតុ

#### *ច.៣.១. ការវិភាគអំពីការប្រើប្រាស់ដីធ្លី*

ក្រុមពិភាក្សាត្រូវប្រើប្រាស់ផែនទីប្រើប្រាស់ដីធ្លី និងទិន្នន័យរបស់វិស័យពាក់ព័ន្ធនានាក្នុងក្រុង ស្រុក ខណ្ឌ ដើម្បីកំណត់ប្រភេទនៃការប្រើប្រាស់ដីធ្លី ភាគរយនៃការប្រើប្រាស់តាមប្រភេទនីមួយៗ (ធៀបនឹងផ្ទៃដីសរុបរបស់ក្រុង ស្រុក ខណ្ឌ) និងវិភាគរកបញ្ហា មូលហេតុ ដំណោះស្រាយ និងតម្រូវការយេនឌ័រនៃដំណោះស្រាយនីមួយៗ។ លទ្ធផលនៃការវិភាគនេះត្រូវស្រង់បញ្ចូលទៅក្នុងតារាង២.៥ ស្តីពីការវិភាគអំពីការប្រើប្រាស់ដីធ្លី។

**តារាង២.៥ ៖ ការវិភាគអំពីការប្រើប្រាស់ដីធ្លី**

| ប្រភេទនៃការប្រើប្រាស់ដីធ្លី | ភាគរយនៃការប្រើប្រាស់ | បញ្ហា | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |

#### *ច.៣.២. ការវិភាគអំពីធនធានធម្មជាតិ*

ក្រុមពិភាក្សាត្រូវកំណត់ ប្រភេទធនធានធម្មជាតិដែលមានក្នុងក្រុង ស្រុក ខណ្ឌ សារៈសំខាន់ក្នុងសេដ្ឋកិច្ច សង្គម របស់ប្រភេទធនធានធម្មជាតិនីមួយៗ ប្រភេទប្រជាជនដែលពឹងផ្អែកលើធនធានធម្មជាតិទាំងនោះសម្រាប់ការទ្រទ្រង់ជីវភាពរស់នៅរបស់ខ្លួន បញ្ហាប្រឈម មូលហេតុ ដំណោះស្រាយ និងតម្រូវការយេនឌ័រនៃដំណោះស្រាយនីមួយ។ លទ្ធផលនៃការវិភាគនេះត្រូវស្រង់បញ្ចូលទៅក្នុងតារាង២.៦ ស្តីពីការវិភាគអំពីធនធានធម្មជាតិ ដូចខាងក្រោម។

**គំរូតារាង២.៦ ៖ ការវិភាគអំពីធនធានធម្មជាតិ**

| ប្រភេទធនធានធម្មជាតិ | សារៈសំខាន់ក្នុងសេដ្ឋកិច្ច សង្គម | អ្នកអាស្រ័យផល (អ្នកមានមុខរបរចម្បង) | បញ្ហា | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |

### ៦.៣.៣. ការវិភាគអំពីបរិស្ថាន

ក្នុងការវិភាគអំពីបរិស្ថាន ក្រុមពិភាក្សាត្រូវកំណត់អំពីបញ្ហាសំខាន់ៗដែលជះឥទ្ធិពលជាអវិជ្ជមាន ឬគំរាមកំហែងដល់បរិស្ថាន និងធ្វើការវិភាគអំពីមូលហេតុ ដំណោះស្រាយ និងតម្រូវការយេនឌ័រនៃដំណោះស្រាយនីមួយៗ។ លទ្ធផលនៃការវិភាគនេះ ត្រូវស្រង់បញ្ចូលទៅក្នុងតារាង២.៧ ស្តីពីការវិភាគអំពីបរិស្ថាន ដូចខាងក្រោម។

**គំរូតារាង២.៧ ៖ ការវិភាគអំពីបរិស្ថាន**

| បញ្ហាសំខាន់ៗ | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ |
|---|---|---|---|
| | | | |
| | | | |
| | | | |

### ៦.៣.៤. ការវិភាគអំពីគ្រោះមហន្តរាយ

ក្នុងការវិភាគអំពីគ្រោះមហន្តរាយ ក្រុមពិភាក្សាត្រូវកំណត់ពីប្រភេទ និងកម្រិតនៃគ្រោះមហន្តរាយដែលធ្លាប់កើតមានជាញឹកញាប់(ក្នុងរយៈពេល៥ឆ្នាំកន្លងមក)បង្កឡើងដោយធម្មជាតិ ដោយមនុស្ស តំបន់ដែលធ្លាប់ទទួលរងគ្រោះ ទំហំនៃការខូចខាត(គិតតាមឆ្នាំ)ដែលកើតឡើងក្នុងក្រុង ស្រុក ខណ្ឌ។ (គប្បីពិចារណាក្នុងការវិភាគដល់កម្រិតឃុំ សង្កាត់ និងឬតំបន់) មូលហេតុ ដំណោះស្រាយ និងតម្រូវការយេនឌ័រនៃដំណោះស្រាយនីមួយៗ។ លទ្ធផលនៃការវិភាគនេះ ត្រូវស្រង់បញ្ចូលទៅក្នុងតារាង២.៨ ស្តីពីការវិភាគអំពីគ្រោះមហន្តរាយដូចខាងក្រោម។

**គំរូតារាង២.៨ ៖ ការវិភាគគ្រោះមហន្តរាយ**

| ប្រភេទគ្រោះមហន្តរាយ | កម្រិតកើតមានក្នុង៥ឆ្នាំកន្លងមក | តំបន់រងគ្រោះ | ទំហំនៃការខូចខាត | | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ |
|---|---|---|---|---|---|---|---|
| | | | ឆ្នាំ | លានរៀល | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

### ៦.៣.៥. ការវិភាគអំពីការប្រែប្រួលអាកាសធាតុ

ក្នុងការវិភាគអំពីការប្រែប្រួលអាកាសធាតុ ក្រុមពិភាក្សាត្រូវកំណត់ពីប្រភេទនៃការប្រែប្រួលអាកាសធាតុ ដែលកើតមានក្នុងក្រុង ស្រុក ខណ្ឌ ផលប៉ះពាល់ តំបន់រងគ្រោះ ក្រុមរងគ្រោះ វិធានការសម្របសម្រួលទៅនឹងការប្រែប្រួលអាកាសធាតុ និងតម្រូវការយេនឌ័រនៃវិធានការសម្របសម្រួលការប្រែប្រួលអាកាសធាតុនីមួយៗ។ លទ្ធផលនៃការវិភាគនេះ ត្រូវស្រង់បញ្ចូលទៅក្នុងតារាង២.៩ ស្តីពីការវិភាគអំពីការប្រែប្រួលអាកាសធាតុ ដូចខាងក្រោម។

**តារាង២.៩ ៖ ការវិភាគអំពីការប្រែប្រួលអាកាសធាតុ**

| ប្រភេទនៃការប្រែប្រួលអាកាសធាតុ | ផលប៉ះពាល់ | តំបន់រងគ្រោះ | ក្រុមរងគ្រោះ | វិធានការសម្របសម្រួល | តម្រូវការយេនឌ័រ |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |

### ច.៤. ការវិភាគផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

ក្នុងការវិភាគផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ត្រូវផ្តោតលើចំណុចសំខាន់ៗមួយចំនួនដូចជា អភិបាលកិច្ច ការងារសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ ការងាររដ្ឋបាលទូទៅ ការគ្រប់គ្រងដែនដី ការងារព្រំដែន និងការងារពាក់ព័ន្ធផ្សេងទៀត ផ្អែកតាមស្ថានភាពជាក់ស្តែងរបស់ក្រុង ស្រុក ខណ្ឌនីមួយៗ។

#### *ច.៤.១. ការវិភាគអំពីសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ*

ក្នុងការវិភាគអំពីសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ក្រុមពិភាក្សាត្រូវផ្តោតការយកចិត្តទុកដាក់លើបញ្ហាសំខាន់ៗ ដែលតែងតែកើតមានក្នុងក្រុង ស្រុក ខណ្ឌ កម្រិតផលប៉ះពាល់នៃបញ្ហាទាំងនោះ មូលហេតុ និងដំណោះស្រាយនៃបញ្ហានីមួយៗ ព្រមទាំងតម្រូវការយេនឌ័រនៃដំណោះស្រាយនីមួយៗ។ លទ្ធផលនៃការវិភាគត្រូវស្រង់ចូលក្នុងតារាង២.១០ ស្តីពីការវិភាគអំពីសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ដូចខាងក្រោម។

**គំរូតារាង២.១០ ៖ ការវិភាគអំពីសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**

| បញ្ហាសំខាន់ៗ | កម្រិតប៉ះពាល់ | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |

#### *ច.៤.២. ការវិភាគអំពីការងាររដ្ឋបាលទូទៅ*

ក្នុងការវិភាគអំពីការងាររដ្ឋបាលទូទៅ ក្រុមពិភាក្សាត្រូវផ្តោតលើបញ្ហាសំខាន់ៗ ដូចជា ការងារអត្រានុកូលដ្ឋាន ធនធានមនុស្សនិងសមត្ថភាព ការគ្រប់គ្រង និងអភិបាលកិច្ចជាដើម។ លទ្ធផលនៃការពិភាក្សាត្រូវស្រង់ចូលក្នុងតារាង ២.១១ ស្តីពីការវិភាគអំពីរដ្ឋបាលទូទៅដូចខាងក្រោម។

**គំរូតារាង២.១១ ៖ ការវិភាគអំពីការងាររដ្ឋបាលទូទៅ**

| បញ្ហាសំខាន់ៗ | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ |
|---|---|---|---|
| | | | |
| | | | |
| | | | |

### ឆ). ការសំយោគលទ្ធផលវិភាគ

បន្ទាប់ពីក្រុមពិភាក្សាតាមផ្នែកនីមួយៗបានបញ្ចប់ការវិភាគ ក្រុមការងារកសាងផែនការត្រូវប្រមូលលទ្ធផល នៃការវិភាគនេះ ទៅធ្វើការសំយោគបញ្ចូលក្នុងតារាង២.១២ “តារាងសំយោគបញ្ហា និងតម្រូវការ” តាមលំដាប់លំដោយដូចខាងក្រោម ៖

- តារាង២.១ ៖ បញ្ចូលក្នុងផ្នែកសេដ្ឋកិច្ច
- តារាង២.២ តារាង២.៣ និងតារាង២.៤ ៖ បញ្ចូលក្នុងផ្នែកសង្គមកិច្ច

- តារាង២.៥ តារាង២.៦ តារាង២.៧ តារាង២.៨ និងតារាង២.៩ ៖ បញ្ចូលក្នុងផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ
- តារាង២.១០ និងតារាង២.១១ ៖ បញ្ចូលក្នុងផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ។

បន្ទាប់ពីសំយោគបញ្ចូលទៅតាមផ្នែកនីមួយៗក្នុងតារាង២.១២រួចមក ក្រុមការងារកសាងផែនការត្រូវរៀបចំកិច្ចប្រជុំមួយដែលស្ថិតក្រោមអធិបតីភាពអភិបាលក្រុង ស្រុក ខណ្ឌ ដើម្បីបង្ហាញលទ្ធផលនៃការសំយោគនេះ ជូនអង្គប្រជុំពិនិត្យ ពិភាក្សា ផ្តល់យោបល់ និងចាត់អាទិភាពនៃដំណោះស្រាយតាមផ្នែកនីមួយៗ។ សមាសភាពចូលរួមក្នុងកិច្ចប្រជុំនេះគឺជាអ្នកចូលរួមក្នុងការវិភាគស្ថានភាពក្រុង ស្រុក ខណ្ឌទាំងអស់ និងអ្នកពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់។

**គំរូតារាង២.១២ ៖ តារាងសំយោគបញ្ហា និងតម្រូវការផ្អែកលើលទ្ធផលវិភាគស្ថានភាពថ្នាក់ក្រុង ស្រុក ខណ្ឌ**

| វិស័យ និងសកម្មភាព | បញ្ហា | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ | អាទិភាព |
|---|---|---|---|---|---|
| **១. ផ្នែកសេដ្ឋកិច្ច** | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| **២. ផ្នែកសង្គមកិច្ច** | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| **៣. ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ** | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| **៤. ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** | | | | | |
| | | | | | |
| | | | | | |
| | | | | | |

បន្ទាប់មក អង្គប្រជុំទាំងមូលត្រូវពិនិត្យតារាង១.៥ តារាងបូកសរុបបញ្ហា និងតម្រូវការរបស់ឃុំ សង្កាត់ និងតារាង២.១២ តារាងសំយោគបញ្ហា និងតម្រូវការ ចេញពីលទ្ធផលនៃការវិភាគស្ថានភាពថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីសំយោគបញ្ចូលគ្នា និងស្រង់បញ្ចូលក្នុងតារាង២.១៣ "តារាងបញ្ហា និងតម្រូវការក្រុង ស្រុក ខណ្ឌ" ដូចខាងក្រោម។ ក្នុងការពិនិត្យនេះ អង្គប្រជុំត្រូវពិនិត្យមើលថា តើមានបញ្ហាសំខាន់អ្វីខ្លះទៀត ដែលបានកំណត់ដោយក្រុមពិភាក្សា ហើយមិនទាន់មានក្នុងតារាង១.៥ ឬបញ្ហាអ្វីខ្លះដែលឃុំ សង្កាត់បានលើកឡើងតែគ្មាននៅក្នុងតារាង២.១២។ បន្ទាប់មកទៀត ក្រុមការងារកសាងផែនការ ត្រូវធ្វើការគណនាអាទិភាពមធ្យមដោយផ្អែកលើអាទិភាពរបស់ឃុំ សង្កាត់ (តារាង១.៥) និងអាទិភាពរបស់ក្រុង ស្រុក ខណ្ឌ (តារាង ២.១២)។

### គំរូតារាង២.១៣ ៖ តារាងបញ្ហា និងតម្រូវការក្រុង ស្រុក ខណ្ឌ

| វិស័យ និង សកម្មភាព | បញ្ហា | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ | អាទិភាព | | |
|---|---|---|---|---|---|---|---|
| | | | | | ឃុំ សង្កាត់ | ក្រុង ស្រុក ខណ្ឌ | ជាមធ្យម |
| **១. ផ្នែកសេដ្ឋកិច្ច** | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| **២. ផ្នែកសង្គមកិច្ច** | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| **៣. ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ** | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| **៤. ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

បន្ទាប់ពីបានរៀបចំតារាង២.១៣ ក្រុមការងារកសាងផែនការ ត្រូវរៀបចំតារាង២.១៤ “តារាងតម្រូវការអាទិភាពក្រុង ស្រុក ខណ្ឌ” ដោយស្រង់ដំណោះស្រាយនានានៃតារាង២.១៣ បញ្ចូលទៅក្នុងតារាង២.១៤ ទៅតាមលំដាប់លំដោយអាទិភាពពីខ្ពស់មកទាប តាមវិស័យ និងផ្នែកនីមួយៗ។

### គំរូតារាង២.១៤ ៖ តារាងតម្រូវការអាទិភាពក្រុង ស្រុក ខណ្ឌ

| វិស័យ និងសកម្មភាព | ដំណោះស្រាយ | តម្រូវការយេនឌ័រ | អាទិភាព |
|---|---|---|---|
| **១. ផ្នែកសេដ្ឋកិច្ច** | | | |
| | | | |
| | | | |
| | | | |
| **២. ផ្នែកសង្គមកិច្ច** | | | |
| | | | |
| | | | |
| | | | |
| **៣. ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ** | | | |
| | | | |
| | | | |
| | | | |
| **៤. ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** | | | |
| | | | |
| | | | |
| | | | |

### ៣.៣.២. ការរៀបចំក្របខ័ណ្ឌអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ

បន្ទាប់ពីការវិភាគស្ថានភាព ក្រុមការងារកសាងផែនការត្រូវរៀបចំកិច្ចប្រជុំ ដើម្បីពិភាក្សា និងរៀបចំចក្ខុវិស័យអភិវឌ្ឍន៍ គោលដៅអភិវឌ្ឍន៍ គោលបំណងអភិវឌ្ឍន៍ សូចនាករ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍។ ក្នុងការរៀបចំក្របខ័ណ្ឌអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ក្រុមការងារកសាងផែនការត្រូវអញ្ជើញតំណាងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការពាក់ព័ន្ធនានារបស់ក្រុមប្រឹក្សា និងអ្នកពាក់ព័ន្ធសំខាន់ៗដែលមានចំណេះដឹង និងបទពិសោធន៍ក្នុងការងារនេះមកចូលរួមផ្តល់យោបល់។

គណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវផ្ញើក្របខ័ណ្ឌអភិវឌ្ឍន៍ដែលបានរៀបចំជូនក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌពិនិត្យ និងអនុម័ត ដើម្បីជាមូលដ្ឋានសម្រាប់គណៈអភិបាលរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល ជាពិសេសការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលលើកទី១។

### ៣.៣.៣. ការរៀបចំយុទ្ធសាស្ត្រតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍

ក្រុមការងារកសាងផែនការ ត្រូវពិភាក្សា និងរៀបចំយុទ្ធសាស្ត្រតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ ដោយផ្តោតលើចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

- យន្តការសម្រាប់តាមដាន និងវាយតម្លៃការអនុវត្តផែនការ
- សូចនាករសំខាន់ៗសម្រាប់តាមដាន និងវាយតម្លៃការអនុវត្តផែនការ
- វិធីសាស្ត្រតាមដាន និងវាយតម្លៃការអនុវត្តផែនការ
- ពេលវេលាសម្រាប់តាមដាន និងវាយតម្លៃការអនុវត្តផែនការ
- ប្រព័ន្ធរៀបចំរបាយការណ៍។

### ៣.៣.៤. ការសរសេរសេចក្តីព្រាងផែនការអភិវឌ្ឍន៍

បន្ទាប់ពីការវិភាគស្ថានភាព ការរៀបចំក្របខ័ណ្ឌអភិវឌ្ឍន៍ និងការរៀបចំយុទ្ធសាស្ត្រតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ ក្រុមការងារកសាងផែនការត្រូវសរសេរសេចក្តីព្រាងផែនការអភិវឌ្ឍន៍បឋម ដើម្បីដាក់ជូនកិច្ចប្រជុំពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានា។ សេចក្តីព្រាងផែនការត្រូវរៀបចំទៅតាមមាតិកា និងសេចក្តីណែនាំ ដូចមានរៀបរាប់នៅក្នុងសេចក្តីពន្យល់ខ្លឹមសារនៃទម្រង់ផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ។

### ៣.៣.៥. កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងបឋមស្តីពីផែនការអភិវឌ្ឍន៍ក្រុង

**ក). គោលបំណង**

គោលបំណងសំខាន់ៗនៃការប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងបឋមស្តីពីផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ គឺ ៖

- បង្ហាញខ្លឹមសារសំខាន់ៗនៃសេចក្តីព្រាងបឋមផែនការអភិវឌ្ឍន៍ ពិសេសក្របខ័ណ្ឌអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ
- ប្រមូលមតិយោបល់ និងអនុសាសន៍ពីអ្នកពាក់ព័ន្ធនានា ដើម្បីធ្វើជាមូលដ្ឋានក្នុងការកែលម្អលើសេចក្តីព្រាងបឋមស្តីពីផែនការអភិវឌ្ឍន៍នេះ។

### ខ). សមាសភាពចូលរួម

កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងបឋមផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ត្រូវស្ថិតក្រោមការដឹកនាំរបស់អភិបាលក្រុង ស្រុក ខណ្ឌ និងមានការចូលរួមពីសមាជិកសំខាន់ៗ រួមមាន ៖

- ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ
- តំណាងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ
- គណៈអភិបាលក្រុង ស្រុក ខណ្ឌ
- ក្រុមការងារកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ
- តំណាងក្រុមប្រឹក្សាគ្រប់ឃុំ សង្កាត់ក្នុងក្រុង ស្រុក ខណ្ឌ
- សមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស និងគណៈកម្មាធិការពាក់ព័ន្ធផ្សេងទៀត
- តំណាងសមាគមក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- តំណាងអង្គការសង្គមស៊ីវិលពាក់ព័ន្ធក្នុងក្រុង ស្រុក ខណ្ឌ
- អ្នកពាក់ព័ន្ធដទៃទៀតតាមការចាំបាច់ ។

### គ). ការរៀបចំត្រៀមសម្រាប់ការប្រជុំ

មុនកិច្ចប្រជុំ ក្រុមការងារកសាងផែនការដោយមានការជួយគាំទ្រពីការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ និងការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុនៃសាលាក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំកិច្ចការសំខាន់ៗ ដូចខាងក្រោម ៖

- រៀបចំរបៀបវារៈនៃកិច្ចប្រជុំ ដែលរួមមាន ៖
  - បទបង្ហាញអំពីខ្លឹមសារសំខាន់ៗនៃសេចក្តីព្រាងផែនការអភិវឌ្ឍន៍
  - ការពិភាក្សា ផ្តល់យោបល់ និងអនុសាសន៍
  - ផ្សេងៗ
- រៀបចំឯកសារបង្ហាញពីខ្លឹមសារសំខាន់ៗនៃសេចក្តីព្រាងបឋមផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ
- រៀបចំលិខិតអញ្ជើញ ដោយភ្ជាប់ជាមួយនូវសេចក្តីព្រាងបឋមស្តីពីផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ និងឯកសារ ពាក់ព័ន្ធផ្សេងទៀត (ឯកសារទាំងនេះត្រូវផ្ញើជូនដល់អ្នកពាក់ព័ន្ធនានាឱ្យបានយ៉ាងតិច៣ថ្ងៃ មុនកិច្ចប្រជុំ)
- កិច្ចការចាំបាច់ផ្សេងៗទៀតតាមការណែនាំរបស់អភិបាលក្រុង ស្រុក ខណ្ឌ ។

### ឃ). ដំណើរការប្រជុំ

បន្ទាប់ពីប្រកាសបើកការប្រជុំ តាមការណែនាំពីប្រធានអង្គប្រជុំ តំណាងក្រុមការងារកសាងផែនការបង្ហាញខ្លឹមសារសង្ខេបនៃសេចក្តីព្រាងបឋមស្តីពីផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ។

បទបង្ហាញត្រូវឆ្លុះបញ្ចាំងពី ៖

- ខ្លឹមសារ នៃចក្ខុវិស័យអភិវឌ្ឍន៍
- គោលដៅ

- គោលបំណង
- សូចនាករ
- យុទ្ធសាស្ត្រអភិវឌ្ឍន៍
- ក្របខណ្ឌចំណាយរយៈពេលមធ្យមដែលបង្ហាញពីតម្រូវការធនធាន
- ការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ

ដើម្បីទទួលបានមតិយោបល់និងអនុសាសន៍ កិច្ចប្រជុំអាចធ្វើការបែងចែកអ្នកចូលរួមជាក្រុមពិភាក្សាតាមការចាំបាច់ លើប្រធានបទសំខាន់ៗមួយចំនួន ដូចជា ចក្ខុវិស័យអភិវឌ្ឍន៍ គោលដៅ គោលបំណង សូចនាករ យុទ្ធសាស្ត្រអភិវឌ្ឍន៍... ។

លទ្ធផលពិភាក្សាតាមក្រុមពិភាក្សាទាំងអស់(បើមាន) ត្រូវយកមកបង្ហាញក្នុងអង្គប្រជុំរួម ។ ក្រុមការងារកសាងផែនការ ត្រូវធ្វើការកត់ត្រារាល់មតិយោបល់ សំណូមពរ និងអនុសាសន៍ទាំងអស់របស់ក្រុមពិភាក្សា និងសំយោគភ្លាមនូវគំនិតយោបល់ទាំងនោះ ដើម្បីជាមូលដ្ឋានសម្រាប់ធ្វើការបូកសរុបលទ្ធផលនៃកិច្ចប្រជុំ និងកែលម្អសេចក្តីព្រាងបឋមស្តីពីផែនការអភិវឌ្ឍន៍ ។

ផ្អែកលើលទ្ធផលនៃកិច្ចប្រជុំពិគ្រោះយោបល់ ក្រុមការងារកសាងផែនការត្រូវពិនិត្យពិចារណាលើគំនិតយោបល់និងអនុសាសន៍ដែលទទួលបាន ដើម្បីធ្វើការកែសម្រួលសេចក្តីព្រាងបឋមស្តីពីផែនការអភិវឌ្ឍន៍ ។

**៣.៣.៦. ការពិនិត្យ និងផ្តល់យោបល់របស់គណៈអភិបាលក្រុង ស្រុក ខណ្ឌលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ**

បន្ទាប់ពីទទួលបានសេចក្តីព្រាងផែនការអភិវឌ្ឍន៍ពីក្រុមការងារកសាងផែនការ គណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំកិច្ចប្រជុំរបស់ខ្លួនដើម្បីពិនិត្យ និងផ្តល់យោបល់ទៅលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ មុននឹងដាក់ជូនគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុង ស្រុក ខណ្ឌពិនិត្យ និងផ្តល់យោបល់ ។

នៅពេលទទួលបានយោបល់ពីគណៈអភិបាលក្រុង ស្រុក ខណ្ឌ ក្រុមការងារកសាងផែនការត្រូវធ្វើការកែសម្រួលសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ឱ្យបានត្រឹមត្រូវទៅតាមយោបល់របស់គណៈអភិបាលក្រុង ស្រុក ខណ្ឌ ។

**២.៣.៧. ការពិនិត្យ និងផ្តល់យោបល់របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុង ស្រុក ខណ្ឌលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ**

បន្ទាប់ពីទទួលបានសេចក្តីព្រាងផែនការអភិវឌ្ឍន៍ពីគណៈអភិបាលក្រុង ស្រុក ខណ្ឌ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុង ស្រុក ខណ្ឌត្រូវរៀបចំកិច្ចប្រជុំរបស់ខ្លួន ដើម្បីពិនិត្យ និងផ្តល់យោបល់ទៅលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ ។

នៅពេលទទួលបានយោបល់ពីគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវណែនាំក្រុមការងារកសាងផែនការ ធ្វើការកែសម្រួលបញ្ចប់សេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ឱ្យបានត្រឹមត្រូវទៅតាមយោបល់របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុង ស្រុក ខណ្ឌ រួចហើយត្រូវដាក់ជូនក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌពិនិត្យ និងអនុម័ត ។

# ជំហានទី៤ ÷ ការអនុម័តផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ

## ៤.១. គោលបំណង

គោលបំណងនៃជំហាននេះ គឺពិនិត្យ អនុម័ត និងផ្សព្វផ្សាយផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌសម្រាប់អាណត្តិរបស់ក្រុមប្រឹក្សា និងប្រើប្រាស់ជាមូលដ្ឋានក្នុងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ក្រុង ស្រុក ខណ្ឌ។

## ៤.២. លទ្ធផលរំពឹងទុក

លទ្ធផលដែលរំពឹងថាសម្រេចបាន គឺផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌរយៈពេលប្រាំឆ្នាំ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ។

## ៤.៣. ដំណើរការ

### ៤.៣.១. ការងារមុនសម័យប្រជុំក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ

ក្រុមការងារកសាងផែនការដោយមានជំនួយពីការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ និងការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុនៃសាលាក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំកិច្ចការសំខាន់ៗដូចខាងក្រោម ៖

- រៀបចំរបៀបវារៈនៃកិច្ចប្រជុំ
- រៀបចំសេចក្តីថ្លែងហេតុ
- រៀបចំឯកសារបង្ហាញអំពីសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ
- រៀបចំលិខិតអញ្ជើញ ដោយភ្ជាប់ជាមួយនូវសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ និងឯកសារពាក់ព័ន្ធផ្សេងៗទៀត (ឯកសារទាំងនេះត្រូវផ្ញើជូនដល់អ្នកពាក់ព័ន្ធនានាឱ្យបានយ៉ាងតិច៣ថ្ងៃ មុនកិច្ចប្រជុំ)
- កិច្ចការចាំបាច់ផ្សេងៗទៀតតាមការណែនាំរបស់អភិបាលក្រុង ស្រុក ខណ្ឌ។

### ៤.៣.២. ការប្រជុំក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ

កិច្ចប្រជុំពិនិត្យ និងអនុម័តលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ត្រូវដំណើរការតាមនីតិវិធី និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ។ របៀបវារៈសំខាន់ៗនៃកិច្ចប្រជុំនេះ រួមមាន ៖

១. សេចក្តីថ្លែងហេតុ និងបទបង្ហាញអំពីសេចក្តីព្រាងផែនការអភិវឌ្ឍន៍ដោយអភិបាលក្រុង ស្រុក ខណ្ឌ

២. ការពិនិត្យ ពិភាក្សា និងអនុម័តសេចក្តីព្រាងផែនការអភិវឌ្ឍន៍

៣. ផ្សេងៗ

### ៤.៣.៣. ការងារក្រោយកិច្ចប្រជុំក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ

#### ក). ការកែសម្រួលសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ

គណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការកែសម្រួលសេចក្តីព្រាងផែនការអភិវឌ្ឍន៍ ដោយផ្អែកតាមការសម្រេចរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ហើយដាក់ជូនអភិបាលក្រុង ស្រុក ខណ្ឌនូវសេចក្តីព្រាងផែនការដែលបានកែសម្រួលនេះ ដើម្បីពិនិត្យ និងផ្ញើជូនអភិបាលរាជធានី ខេត្តពិនិត្យ និងផ្តល់អនុលោមភាព។

## ខ). ការផ្តល់អនុលោមភាពលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌដោយអភិបាលរាជធានី ខេត្ត

បន្ទាប់ពីទទួលបានសេចក្តីព្រាងផែនការអភិវឌ្ឍន៍ពីអភិបាលក្រុង ស្រុក ខណ្ឌ អភិបាលរាជធានី ខេត្តត្រូវរៀបចំកិច្ចប្រជុំរបស់ខ្លួន ដើម្បីពិនិត្យ និងផ្តល់អនុលោមភាពលើសេចក្តីព្រាងផែនការនេះ ដោយសហការយ៉ាងជិតស្និទ្ធជាមួយមន្ទីរ អង្គភាពពាក់ព័ន្ធនានា។

ការពិនិត្យ និងផ្តល់យោបល់របស់អភិបាលរាជធានី ខេត្ត លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ត្រូវផ្តោតលើភាពស្របច្បាប់ និងសង្គតិភាពរបស់ផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ជាមួយនឹងគោលនយោបាយជាតិ ច្បាប់ និងលិខិតបទដ្ឋាននានា។

អភិបាលរាជធានី ខេត្ត ត្រូវពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌក្នុងរយៈពេល៣០ថ្ងៃ គិតពីថ្ងៃដែលទទួលបានការស្នើសុំពិនិត្យ និងផ្តល់យោបល់ពីអភិបាលក្រុង ស្រុក ខណ្ឌ។ ក្នុងរយៈពេល៣០ថ្ងៃនេះ រួមមានពេលវេលាចំណាយសម្រាប់ការធ្វើទំនាក់ទំនងរវាងអភិបាលក្រុង ស្រុក ខណ្ឌ ជាមួយនឹងអភិបាលរាជធានី ខេត្ត ដើម្បីស្រាយបំភ្លឺ និងឯកភាពលើយោបល់ដែលផ្តល់ដោយអភិបាលរាជធានី ខេត្ត លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ។

ក្នុងករណី មិនមានការឯកភាពគ្នារវាងអភិបាលក្រុង ស្រុក ខណ្ឌ និងអភិបាលរាជធានី ខេត្ត អំពីខ្លឹមសារនៃសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ អភិបាលរាជធានី ខេត្តត្រូវរាយការណ៍ និងស្នើសុំមកលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីធ្វើការសម្របសម្រួលដោះស្រាយ។

ក្នុងរយៈពេល៣០ថ្ងៃ បើគ្មានការឆ្លើយតបជាលាយល័ក្ខណ៍អក្សរពីអភិបាលរាជធានី ខេត្តទៅអភិបាលក្រុង ស្រុក ខណ្ឌទេ នោះសេចក្តីព្រាងផែនការអភិវឌ្ឍន៍ ត្រូវចាត់ទុកថាទទួលបានអនុលោមភាពពីអភិបាលរាជធានី ខេត្ត។

ក្នុងការពិនិត្យ និងផ្តល់យោបល់ទៅលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ អភិបាលរាជធានី ខេត្ត ត្រូវពិចារណាអំពីភាពស្របច្បាប់ និងសង្គតិភាពនៃខ្លឹមសារផែនការអភិវឌ្ឍន៍ទៅនឹងគោលនយោបាយជាតិ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។

ក្នុងករណីមានយោបល់កែសម្រួលលើសេចក្តីផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ដោយអភិបាលរាជធានី ខេត្ត គណៈអភិបាលក្រុង ស្រុក ខណ្ឌធ្វើការពិចារណា និងកែសម្រួលសេចក្តីព្រាងផែនការអភិវឌ្ឍន៍ទៅតាមយោបល់ដែលទទួលបាន ហើយដាក់ជូនក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ ពិនិត្យ និងអនុម័តឡើងវិញ ដោយផ្តោតតែទៅលើចំណុច ដែលបានកែសម្រួលប៉ុណ្ណោះ។

## គ). សេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ

បន្ទាប់ពីការអនុម័តរបស់ក្រុមប្រឹក្សា គណៈអភិបាលត្រូវរៀបចំសេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ និងដាក់ជូនប្រធានក្រុមប្រឹក្សាចុះហត្ថលេខា។

## ឃ). ការបោះពុម្ពសៀវភៅផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ

គណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំបោះពុម្ពសៀវភៅផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ បែងចែកផ្សព្វផ្សាយជាសាធារណៈ និងតម្កល់ទុកនៅសាលាក្រុង ស្រុក ខណ្ឌ ការិយាល័យផែនការក្រុង ស្រុក ខណ្ឌ និងផ្ញើទៅក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអ្នកពាក់ព័ន្ធដទៃទៀត។

## ង). ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍

បន្ទាប់ពីផែនការអភិវឌ្ឍន៍ត្រូវបានអនុម័ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌត្រូវធ្វើការណែនាំឱ្យគណៈអភិបាលក្រុង ស្រុក ខណ្ឌ ចាត់ចែងការអនុវត្តផែនការអភិវឌ្ឍន៍នេះ ដោយមានតម្លាភាព មានគណនេយ្យភាព មានការចូលរួម និងមានប្រសិទ្ធភាព។

ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌត្រូវទទួលខុសត្រូវក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃជារៀងរាល់ឆ្នាំលើការអនុវត្តផែនការអភិវឌ្ឍន៍ដោយរាប់ទាំងផ្នែកនៃផែនការអភិវឌ្ឍន៍ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ៖

- ក្រុមប្រឹក្សាប្រភេទរួមគ្នា
- ប្រភេទក្រុមប្រឹក្សាផ្សេងៗទៀត
- ក្រសួង ស្ថាប័ន អង្គភាពនានារបស់រាជរដ្ឋាភិបាល
- អ្នកពាក់ព័ន្ធនានា។

ក្នុងការអនុវត្តជាក់ស្តែង ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ គឺសំដៅលើការតាមដានត្រួតពិនិត្យ និងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល និងបណ្តាសកម្មភាពនានាដែលអនុវត្តដោយអង្គការសង្គមស៊ីវិល និងផ្នែកឯកជននៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ។

ដូច្នេះ ការរៀបចំយុទ្ធសាស្ត្រតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ ត្រូវផ្តោតលើចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

- ការរៀបចំផែនការតាមដាន និងវាយតម្លៃការអនុវត្តផែនការ
- ការកំណត់សូចនាករសម្រាប់តាមដាន និងវាយតម្លៃការអនុវត្តផែនការ
- អ្នកទទួលខុសត្រូវក្នុងការតាមដាន និងវាយតម្លៃការអនុវត្តផែនការ
- វិធីសាស្ត្រតាមដាន និងវាយតម្លៃការអនុវត្តផែនការ
- អ្នកចូលរួមក្នុងការតាមដាន និងវាយតម្លៃការអនុវត្តផែនការ។

នៅចុងឆ្នាំនីមួយៗ គណៈអភិបាលត្រូវរៀបចំ និងដាក់ជូនរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តផែនការអភិវឌ្ឍន៍ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។ ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវផ្ញើជូនរបាយការណ៍ស្តីពីការអនុវត្តផែនការទៅគ្រប់ភាគីពាក់ព័ន្ធទាំងអស់។

ខ្លឹមសាររបាយការណ៍នេះរួមមាន ៖

- វឌ្ឍនភាពការងារអនុវត្តក្នុងឆ្នាំកន្លងមក
- ទិសដៅការងារសម្រាប់អនុវត្តឆ្នាំខាងមុខ
- សេចក្តីសន្និដ្ឋានរួម។

ក្រៅពីរបាយការណ៍ប្រចាំឆ្នាំ គណៈអភិបាលក្រុង ស្រុក ខណ្ឌត្រូវរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តផែនការអភិវឌ្ឍន៍ និងរបាយការណ៍ផ្សេងទៀត ដើម្បីរាយការណ៍ជូនក្រុមប្រឹក្សាជាប្រចាំ។

ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អាចធ្វើការកែតម្រូវផែនការអភិវឌ្ឍន៍ក្នុងអំឡុងពេលនៃការ អនុវត្តផែនការនេះ ផ្អែកតាមការស្នើសុំកែតម្រូវរបស់គណៈអភិបាលក្រុង ស្រុក ខណ្ឌ។